Guide.qxp 1/03/2005 4:10 PM Page 1

## សៀវភៅណែនាំសំរាប់

# អនុវត្តន៍ តាមដានត្រួតពិនិត្យ និង វាយតំលៃ

## ផែនការអប់រំសំរាប់ទាំងអស់គ្នាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

អង្គការ អប់រំ វិទ្យាសាស្ត្រ
និង វប្បធម៌ នៃ សហប្រជាជាតិ
យូណេស្កូ ភ្នំពេញ

Guide.qxp 1/03/2005 4:10 PM Page 2

*ចំណងជើងដែលបានយកមកប្រើ និង ការបង្ហាញសម្ភារៈនៅក្នុងការបោះពុម្ពផ្សាយនេះ មិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់យូណេស្កូទាក់ទងទៅនឹងស្ថានភាពស្របច្បាប់ នៃប្រទេសណាមួយ ទឹកដី ទីក្រុង ឬ តំបន់ណាមួយ ឬនៃសិទ្ធិអំណាចរបស់ខ្លួន ឬ ទាក់ទង ទៅនឹងការកំណត់នូវព្រំដែន ឬ ព្រំប្រទល់របស់ខ្លួនឡើយ។*

*ការបកប្រែជាភាសាខ្មែរធ្វើឡើងក្រោមបន្ទុករបស់ការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ។*

ឯកសារដើមជាភាសាអង់គ្លេស
បោះពុម្ពនៅឆ្នាំ២០០៣ ដោយការិយាល័យយូណេស្កូ
ប្រចាំភូមិភាគអាស៊ីប៉ាស៊ីហ្វិកផ្នែកអប់រំ
P.O.Box 967, Prakanong Post Office
Bangkok 10110. Thailand
បោះពុម្ពនៅប្រទេសថៃ
Original title in English
© UNESCO 2004

ឯកសារជាភាសាខ្មែរ
បោះពុម្ពនៅឆ្នាំ២០០៤ ដោយការិយាល័យយូណេស្កូនៅភ្នំពេញ
អគារលេខ ៣៨ មហាវិថីសម្តេចសុធារស
សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ភ្នំពេញ
បកប្រែអត្ថបទជាភាសាខ្មែរដោយ: ឈិន និត
រូបថតនៅក្របមុខដោយ: ខៀវ វិជ្ជានន្ទ
ក្រាហ្វិកដោយ: ណាំង វ៉ារុធ
បោះពុម្ពលើកទី ១ ដោយរោងពុម្ព គីម ឡុង
ចំនួន ១០០០ ច្បាប់

© UNESCO 2004, for the Khmer translation

# អារម្ភកថា

## ជូនចំពោះអ្នកអនុវត្តការងារអប់រំសំរាប់ទាំងអស់គ្នា

សៀវភៅនេះជាសៀវភៅមួយដែលបានកែលំអពីគោលការណ៍ណែនាំសំរាប់រៀបរៀងផែនការអប់រំសំរាប់ទាំងអស់គ្នា ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ដែលបានបោះពុម្ពកាលពីខែមីនាឆ្នាំ ២០០២ ។ សៀវភៅនេះជាជំនួយស្មារតីសំរាប់អ្នករៀបរៀងផែនការអោយចេះធ្វើផែនការអប់រំសំរាប់ទាំងអស់គ្នាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ។ ដោយសារការចែកចាយសៀវភៅនេះមានលក្ខណៈទូលំទូលាយ ហើយ ដោយសារបានផ្សព្វផ្សាយឱ្យអ្នកធ្វើផែនការអប់រំសំរាប់ទាំងអស់គ្នាបានយល់ជ្រួតជ្រាប ទើបផែនការអប់រំសំរាប់ទាំងអស់គ្នាជាច្រើន បានយកចិត្តទុកដាក់លើគោលដៅសមភាពយេនឌ័រគិតជាតួលេខ និង សមភាពយេនឌ័ររួមរបស់ក្របខ័ណ្ឌសកម្មភាពក្រុងដាកា និង គោលដៅអភិវឌ្ឍន៍សហស្សវត្ស ។ ប៉ុន្តែ យើងទាំងអស់គ្នាដឹងហើយថា គោលនយោបាយ និង ផែនការដែលមិនទាន់អនុវត្ត និង តាមដាន គឺមិនទាន់បានកែប្រែ ឬ កែលំអឡើយ។ កាលពីប៉ុន្មានឆ្នាំមុន យើងមានចំណាប់អារម្មណ៍ល្អៗជាច្រើនអំពីបំណងអនុវត្តន៍ ប៉ុន្តែ មិនបានទទួលលទ្ធផលជាផ្លែផ្កាគួរឱ្យចង់បានឡើយ កាលនោះ យើងមិនទាន់មានផែនការអនុវត្តដែលសមស្របនៅឡើយ។

គោលការណ៍ណែនាំនេះមានគោលបំណងសំដៅផ្តល់យោបល់ ឬ ណែនាំអំពីការធានាឱ្យដំណើរការអនុវត្ត និង តាមដានផែនការអប់រំសំរាប់ទាំងអស់គ្នា មានលក្ខណៈឆ្លើយតបនឹងតម្រូវការយេនឌ័រ។ គោលការណ៍ណែនាំនេះ ក៏មានប្រយោជន៍សំរាប់អនុវត្តផែនការអប់រំទូទៅផងដែរ ។ គោលការណ៍នេះដកស្រង់បទពិសោធន៍ ដែលបានអនុវត្តជាច្រើនឆ្នាំកន្លងមក ជាពិសេស កាលពី២ឆ្នាំថ្មីៗនេះ ក្រោយពីមានបណ្តាញយេនឌ័រក្នុងវិស័យអប់រំរបស់អាស៊ី (GENIA)។ បណ្តាញនេះប្រមូលផ្តុំជនបង្គោលទទួលបន្ទុក យេនឌ័ររបស់ក្រសួងអប់រំនៅអាស៊ី ។ តាមរយៈជំនួយសហមេត្រី និង កិច្ចប្រឹងប្រែងរួម បណ្តាញនេះបានបង្កើតឧបករណ៍មួយចំនួនដើម្បីជាយានសំរាប់បញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងអប់រំនៅអាស៊ី ។ ដូចនេះ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងមានប្រយោជន៍ សំរាប់លើកកំពស់សមភាពយេនឌ័រនៅក្នុងវិស័យអប់រំយ៉ាងពិតប្រាកដ ។ សំរាប់ព័ត៌មានបន្ថែម សូមអានវេបសាយយេនឌ័រ និង សមភាព (www.unescobkk.org/gender) ឬ ផ្ញើសំណូមពរ និង គំនិតកែលំអតាមរយៈអ៊ីមេល gender@unesco.org .

Sheldon Shaeffer

**នាយក**

**ការិយាល័យ យូណេស្កូ ប្រចាំអាស៊ីប៉ាស៊ីហ្វិចសំរាប់អប់រំ**

Guide.qxp 1/03/2005 4:10 PM Page 5

# មាតិកា


សេចក្តីផ្តើម ១

វិភាគស្ថានភាពឱ្យបានល្អិតល្អន់ ឱ្យគ្រប់ជ្រុងជ្រោយ
ហើយកំណត់រកបញ្ហាពាក់ព័ន្ធឱ្យសព្វគ្រប់ ៤

ការកំណត់គោលបំណង និង ការស្វែងរកយុទ្ធសាស្ត្រ ១៨

ការអនុវត្ត ការតាមដានត្រួតពិនិត្យ និង ការវាយតំលៃ ២១

តំរូវការថវិកា និង ធនធានមនុស្ស និង ភាពជាដៃគូ ២៦

ព័ត៌មាន និង ធនធានផ្សេងៗទៀត ២៨


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ បញ្ជីត្រួតពិនិត្យការបញ្ជ្រាបយេនឌ័រ
នៅក្នុងការអប់រំសំរាប់ទាំងអស់គ្នា ៣៥

ឧបសម្ព័ន្ធ ២ សំណួរសំខាន់ពីយេនឌ័រសំរាប់ពិចារណា
បង្កើតកម្មវិធីសិក្សា និង សៀវភៅសិក្សា
ដែលមិនមានលំអៀងយេនឌ័រ ៣៩

Guide.qxp 1/03/2005 4:10 PM Page 7

# សេចក្តីផ្តើម

## សាវតារ

រង្វាយតំលៃលើការអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០០ បានបង្ហាញថា ការលើកកំពស់ការចូលរៀននៅបឋមសិក្សាមានការរីកចំរើន ហើយនៅកន្លែងខ្លះមានការរីកចំរើនគួរឱ្យកត់សំគាល់ ។ ប៉ុន្តែ ការបង្រួញគម្លាតយេនឌ័រនៅកន្លែងជាច្រើនបានសំរេចបន្តិចបន្តួច ឬ មិនបានសំរេចសោះ។ នៅពេលដែលរដ្ឋាភិបាលនានាឃើញលទ្ធផលរកឃើញទាំងនេះ កាលពីនៅវេទិកាអប់រំពិភពលោកនៅក្រុងដាកា ប្រទេសសេនេហ្គាល ខែមេសា ឆ្នាំ ២០០០ រដ្ឋាភិបាលទាំងនោះ បានសំរេចបង្កើនការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីលុបបំបាត់គម្លាតយេនឌ័រ ហើយបានប្តេជ្ញាថា សំរេចសមភាពយេនឌ័រឱ្យបាននៅឆ្នាំ២០១៥។ នៅពិធីបើកសន្និសីទនៅទីក្រុងដាកានេះ លោក កូហ្វី អាណាន់ អគ្គលេខាធិការ អង្គការសហប្រជាជាតិ បានថ្លែងសេចក្តីប្តេជ្ញាចិត្តយ៉ាងមុតមាំសំរាប់ប្រព័ន្ធអង្គការសហប្រជាជាតិទាំងអស់ឱ្យយកចិត្តទុកដាក់លើបញ្ហានេះ ដោយប្រកាសគំនិតផ្តួចផ្តើមអង្គការសហប្រជាជាតិស្តីពីការអប់រំសំរាប់កុមារី។

## ការប្តេជ្ញាចំពោះសមភាពយេនឌ័រ នៅទីក្រុងដាកា ខែមេសា ឆ្នាំ២០០០

**គោលដៅទី ២:** ធានាថានៅឆ្នាំ២០១៥ កុមារទាំងអស់ជាពិសេស កុមារីមានលទ្ធភាពទទួលការអប់រំ និង បញ្ចប់ការអប់រំប្រកបដោយគុណភាព ដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច។

**គោលដៅទី ៤:** សំរេចឱ្យបាន ៥០ ភាគរយ នូវការបង្កើនអក្ខរកម្មមនុស្សចាស់ នៅឆ្នាំ ២០១៥ ជាពិសេសសំរាប់ស្ត្រី ។

**គោលដៅទី ៥:** លុបបំបាត់វិសមភាពយេនឌ័រគិតជាតួលេខក្នុងការអប់រំបឋមសិក្សា និង មធ្យមសិក្សា ឱ្យបាននៅឆ្នាំ២០០៥ ហើយសំរេចឱ្យបានសមភាពយេនឌ័រក្នុងការអប់រំនៅឆ្នាំ២០១៥ ដោយធានាឱ្យកុមារីមានលទ្ធភាពពេញលេញ និងស្មើភាពក្នុងការទទួលការអប់រំមូលដ្ឋាន និងសំរេចជោគជ័យក្នុងការសិក្សា។

Guide.qxp 1/03/2005 4:10 PM Page 8

# កិច្ចព្រមព្រៀងក្នុងចំណោមបណ្តាប្រទេសនៅអាស៊ី និង ប៉ាស៊ីហ្វិកកាលពីនៅបាងកក ខែមករា ឆ្នាំ ២០០០

ក្រុមខណ្ឌសកម្មភាព[១] ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកបញ្ជាក់ថាៈ

*"ចាំបាច់ត្រូវលុបបំបាត់វិសមភាពយេនឌ័រក្នុងគ្រប់ប្រព័ន្ធទាំងអស់ ដែលកើតមានឡើងក្នុងចំណោមកុមារី និង កុមារាទូទាំងប្រព័ន្ធអប់រំ ដូចជាការចុះឈ្មោះចូលរៀន ការសំរេចលទ្ធផលសិក្សា និង បញ្ចប់ការសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងកម្មវិធីសិក្សា និង ក្នុងសកម្មភាពរៀន និង បង្រៀន ។ ភាពត្រូវកិច្ចនេះទាមទារការយល់ដឹងច្បាស់ និង ឱ្យតំលៃខ្ពស់ទៅលើតួនាទីអប់រំ ដែលជាយានសំរាប់ធានាឱ្យមានសមភាពសំរាប់ស្ត្រី និង សំរាប់ផ្តល់សិទ្ធិ និង អំណាចដល់ស្ត្រី ។"*

## តើលុបបំបាត់គម្លាតយេនឌ័រ និង សមភាពយេនឌ័រ មានន័យយ៉ាងដូចម្តេច?

លុបបំបាត់គម្លាតយេនឌ័រ និង វិសមភាពយេនឌ័រ មានន័យថាធ្វើយ៉ាងណាឱ្យភាពមិនល្អរវាងភេទ មានការពេញចិត្តទាំងអស់គ្នា ។ ធានាថា ភេទទាំងពីររៀនចប់ពីសាលា មានការអប់រំមួយដែលផ្តល់នូវបំណិនជីវិត និង អនុញ្ញាតឱ្យភេទទាំងពីរបន្តការសិក្សាទៅថ្នាក់ឧត្តម ឬ ថ្នាក់វិជ្ជាជីវៈ ហើយមិនមានការបែងចែកតាមទម្លាប់មិនល្អរបស់ប្រពៃណីយេនឌ័រឡើយ។ សំខាន់ជាងគេបំផុត ភេទទាំងពីរត្រូវទទួលបានជំនាញ និង ឥរិយាបថដែលធានាឱ្យគេប្រើប្រាស់សក្តានុភាពរបស់គេដោយមិនប្រកាន់ភេទ។ នៅប្រទេសភាគច្រើន កុមារីច្រើនចាត់ទុកជាភេទទន់ខ្សោយ ប៉ុន្តែតាមការពិត ក្នុងករណីខ្លះ ក៏មានក្មេងប្រុសទន់ខ្សោយជាងក្មេងស្រី នៅក្នុងប្រព័ន្ធអប់រំ និង សេដ្ឋកិច្ចសង្គមកិច្ចដែរ។ អ្នកប្រើប្រាស់ពាក្យទាំងនេះត្រូវប្រើពាក្យក្មេងប្រុស និង ក្មេងស្រី តាមដែលសមស្រប ។ សូមស្វែងយល់បន្ថែមអំពីពាក្យយេនឌ័រ ក្នុងវគ្គមួយនិយាយអំពីបញ្ញត្តិគន្លឹះ នៅចុងបញ្ចប់នៃឯកសារនេះ ។

---

១. អនុម័តនៅសន្និសីទអាស៊ីប៉ាស៊ីហ្វិកស្តីពីការវាយតម្លៃអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០០ ក្នុងបាងកក ១៧-២០ មករា ២០០០។

Guide.qxp 1/03/2005 4:10 PM Page 9

## ភារកិច្ចចំពោះមុខ

ភារកិច្ចចំពោះមុខដែលត្រូវបំពេញឱ្យបានគឺ កំណែទំរង់ប្រព័ន្ធអប់រំដែលឱ្យប្រព័ន្ធនេះផ្តល់ឱកាសស្មើៗគ្នាដល់កុមារទាំងអស់ ហើយផលិតពលរដ្ឋដែលអាចចូលរួមក្នុងសមត្ថភាពដូចគ្នា ក្នុងការអភិវឌ្ឍ សង្គមប្រជាធិបតេយ្យគ្មានការរើសអើង និង មិនប្រកាន់ភេទ ។ ជំហានទីមួយ ក្នុងទិសដៅនេះគឺធានាថា ផែនការអប់រំសំរាប់ទាំងអស់គ្នាមានបញ្ចូលយេនឌ័រ និង ឆ្លើយតបនឹងតំរូវការយេនឌ័រ មានទិសដៅ និង យុទ្ធសាស្ត្រជាក់លាក់ ហើយបានទទួលមូលនិធិ និង ធនធានមនុស្សសំរាប់អនុវត្ត និង តាមដានការរីកចំរើនឈានទៅសំរេចគោលដៅទាំងអស់នេះ។ គួរកត់សំគាល់ថា ប្រទេសនានាត្រូវមានផែនការអប់រំសំរាប់ទាំងអស់គ្នាយ៉ាងលំអិតច្បាស់លាស់ ត្រូវមានកម្មវិធីអប់រំសំរាប់ទាំងអស់គ្នាយ៉ាងលំអិតនៅក្នុងផែនការអភិវឌ្ឍន៍វិស័យអប់រំជាតិ ដែលឆ្លើយតបនឹងតំរូវការយេនឌ័រ ហើយមិនត្រូវមានផែនការដោយឡែកសំរាប់ការអប់រំកុមារី និង ស្ត្រីឡើយ ។ លក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃផែនការទាំងនេះ រួមមាន វិសាលភាពនៃតំរូវការឆ្លើយតបនឹងយេនឌ័រ ហើយនិង លក្ខណៈដែលមានឥទ្ធិពលសំរាប់ផ្តល់ មូលនិធិ ។

## បែបបទធ្វើផែនការ

ដូចមានចែងក្នុងគោលការណ៍ណែនាំរបស់អង្គការ យូណេស្កូ សំរាប់រៀបចំផែនការ[២] អប់រំសំរាប់ទាំងអស់គ្នា បែបបទធ្វើផែនការ ត្រូវមានការចូលរួមពីច្រើនភាគី និង មានកិច្ចព្រមព្រៀងរួម និង បង្កើតជាដៃគូ ។ ក្នុងន័យនេះត្រូវធានាថា អង្គការស្ត្រី និង សកម្មជនអប់រំជាស្ត្រី បានចូលរួមក្នុងវេទិកាអប់រំសំរាប់ទាំងអស់គ្នា ហើយធានាថា អ្នកជំនាញយេនឌ័រទាំងប្រុស ទាំងស្រី បានចូលរួមក្នុងក្រុមធ្វើផែនការ និង ពង្រាងផែនការសំខាន់ ដូចគ្នានេះដែរ គឺធ្វើយ៉ាងណាឱ្យអ្នកចែងគោលនយោបាយទាំងប្រុស ទាំងស្រី យល់អំពីបញ្ហាយេនឌ័រ ដូច្នេះ អ្នកចែងគោលនយោបាយនឹងចាត់ទុកថា ការអប់រំដែលមានបញ្ចូលយេនឌ័រពិតជាមានសារប្រយោជន៍សំរាប់អ្នករៀនទាំងប្រុសទាំងស្រី និង សំរាប់សង្គមទាំងមូល ។

២ ការរៀបចំផែនការសកម្មភាពជាតិ : សេចក្តីណែនាំប្រចាំប្រទេស UNESCO 2000

# វិភាគស្ថានភាពឱ្យបានល្អិតល្អន់ ឱ្យគ្រប់ជ្រុងជ្រោយ ហើយកំណត់រកបញ្ហាពាក់ព័ន្ធឱ្យសព្វគ្រប់

## ១. អប់រំបឋមសិក្សា និង មធ្យមសិក្សាចំណេះទូទៅ

នៅពេលធ្វើវិភាគស្ថានភាព និង កំណត់រកបញ្ហាទាក់ទងនឹងការអប់រំសំរាប់ កុមារី និង ស្ត្រី មានសំណួរជាច្រើន គួរចោទសួរជាចាំបាច់ ៦ និយាយពីការ អប់រំបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅត្រូវពិចារណាលើបញ្ហា ដូចជា លទ្ធភាពទទួលការអប់រំ គុណភាព កត្តាពាក់ព័ន្ធ និង ការគ្រប់គ្រង ៦

### *ក. លទ្ធភាពទទួលការអប់រំ*

ចំលើយគួរឆ្លើយនឹងសំណួរមួយចំនួនដូចខាងក្រោម :

- តើអត្រាចុះឈ្មោះចូលរៀន និងអត្រារៀនចប់ថ្នាក់មានប៉ុន្មាន? ដោយបង្ហាញពីភាពខុសគ្នាតាមតំបន់ភូមិសាស្ត្រ ក៏តែគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន (ឧទាហរណ៍ខេត្ត ឬ ស្រុក) តាមជនបទ ទីក្រុង ទីប្រជុំជន តាមភេទ និង ក្រុមមនុស្សស្ថិតក្នុងស្ថានភាពលំបាកនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា?
- តើដំណាក់កាលចំបងបំផុតក្នុងការឡើងថ្នាក់នៅក្នុងប្រព័ន្ធអប់រំមានអ្វីខ្លះ ដោយរាយទៅតាមភេទ (ពីថ្នាក់ទី១ ដល់ទី២ ទី៤ ដល់ទី៥ ពីបឋមសិក្សា ដល់មធ្យមសិក្សាបឋមភូមិ ពីមធ្យមសិក្សាបឋមភូមិ ដល់ មធ្យមសិក្សាទុតិយភូមិជាដើម)តើអ្វីជាដើមហេតុបង្កឱ្យមានវិសមភាពយេនឌ័រ?
- តើសាលារៀនមានចំនួនប៉ុន្មាន ហើយរបាយសាលារៀនមានលក្ខណៈយ៉ាងដូចម្តេចនៅតាមស្រុក ធៀបនឹងចំនួនប្រជាជន?
- តើក្មេងៗត្រូវចំណាយពេលប៉ុន្មានដើម្បីធ្វើដំណើរទៅសាលារៀន? ហើយតើកត្តាទាំងនោះប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្សយ៉ាងដូចម្តេច? (កត្តាផ្សេងៗ ដូចជា ស្ថានភាពផ្លូវ និង មធ្យោបាយធ្វើដំណើរ?

៦ This part of this document is based on the United Nations Girls Education Initiatives (UNGEI) Guidance Note to UN country teaams, November 2001.

**ដើម្បីឆ្លើយនឹងសំណួរទាំងនេះ** ជំហានទីមួយ ត្រូវប្រើប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំជាតិ (EMIS) ដែលសំបូរព័ត៌មាន ។ ប៉ុន្តែ ក្នុងករណីខ្លះ ក៏ត្រូវការទិន្នន័យដែលមានតួលេខខុសគ្នារវាងភេទនីមួយៗផងដែរ។ លើសនេះទៀត ប្រហែលជាត្រូវការការស្រាវជ្រាវបែបពណ៌នាលំអិត ដើម្បីស្វែងយល់អំពីដើមហេតុ ដែលបង្កឱ្យមានវិសមភាពយេនឌ័រក្នុងការចុះឈ្មោះចូលរៀន ។ ចំងាយផ្លូវពីផ្ទះទៅសាលារៀន មធ្យោបាយធ្វើដំណើរ ក៏ជាបញ្ហាដែលត្រូវការសិក្សាស្រាវជ្រាវមួយយ៉ាងពិសេសផងដែរ។ផ្អែកលើបរិបទ បញ្ហាឯទៀត ដែលបណ្តាលឱ្យកុមារមិនអាចទទួលបានការអប់រំ ហើយនិង ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យ រួមមាន:

- ភាសាកំណើត និង ភាសាបង្រៀន
- សិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិក្នុងការចុះបញ្ជីនគោលដ្ឋាន
- គំរែអប់រំផ្លូវការ និង ក្រៅផ្លូវការ
  កង្វះខាតសេវាកម្មសំរាប់ចរជន ឬ ជនអន្តោប្រវេសន៍

## ខ. គុណភាព និង កត្តាពាក់ព័ន្ធ

គុណភាព និង កត្តាពាក់ព័ន្ធជារឿងសំខាន់សំរាប់ការចូលរៀនរបស់ក្មេងប្រុស និង ក្មេងស្រី ប៉ុន្តែនៅប្រទេសខ្លះ បញ្ហាទាំងនេះមានឥទ្ធិពលទៅលើក្មេងស្រីជាងក្មេងប្រុស ។ ដោយសារកុមារីមានការទទួលខុសត្រូវច្រើនក្នុងគ្រួសារ ហើយដោយសារការចំណាយប្រយោលទៅលើការរៀនសូត្ររបស់កូនស្រីមានកំរិតខ្ពស់ កូនស្រីត្រូវមានពេលវេលាតិចតួច ឬ គ្មានពេលទំនេរ។ ដូចនេះ ពេលវេលានៅសាលាត្រូវតែប្រើប្រាស់ឱ្យមាន ប្រសិទ្ធភាពបំផុត។ បើមាតាបិតាយល់ថា ពេលវេលាទៅសាលាជាការឥតប្រយោជន៍ នោះក្មេងស្រីប្រហែលជាត្រូវប្រឈមមុខនឹងការដកចេញពីសាលាដើម្បីឱ្យធ្វើការផ្សេងដែលមានប្រយោជន៍សំរាប់ជីវភាពរស់នៅរបស់គ្រួសារ។

**សំណួរគន្លឹះដែលត្រូវពិចារណារួមមាន :**

- ១. បរិយាកាសសិក្សា[២]

  តើគុណភាពជារូបវ័ន្តរបស់សាលារៀនមានអ្វីខ្លះ? តើអគារសាលារៀនមានសុវត្ថិភាព និង អាចប្រើប្រាស់បានដែរឬទេ? តើនៅក្នុងសាលារៀន មានទឹកស្អាតបរិភោគ ហើយមានបង្គន់
- ដាច់ដោយឡែកសំរាប់ក្មេងស្រី និង ក្មេងប្រុសដែរឬទេ? តើគុណភាពនៃបរិយាកាសសិក្សាជាអ្វី? តើបរិយាកាសនោះមាន
- លក្ខណៈឱ្យសិស្សចូលចិត្ត និង មានផាសុកភាពដែរឬទេ?

---

២ សំណួរគន្លឹះសំរាប់ពិចារណាបែងចែកជាប្រាំប្រភេទ រួមមាន បរិយាកាសសិក្សា ខ្លឹមសារមេរៀន ការសិក្សារបស់សិស្ស សកម្មភាពសិក្សា និង លទ្ធផលសិក្សាដកស្រង់ចេញពី UNICEF

តើបរិយាកាសសិក្សា បង្កលក្ខណៈឱ្យសិស្សចង់ចេះចង់ដឹង និងជាកន្លែងគាំទ្រឱ្យសិស្សប្រុស និង សិស្សស្រីយកមកអនុវត្តតាមដែរឬទេ?តើសាលារៀនមានលោកគ្រូ និង អ្នកគ្រូ ដែលជាគំរូឱ្យសិស្សអនុវត្តតាមនៅថ្នាក់បឋមសិក្សា និង មធ្យមសិក្សាដែរឬទេ? តើបរិយាកាសសិក្សាផ្តល់ឱកាសដូចៗគ្នា សំរាប់កុមារី និងកុមារាក្នុងការចូលរួម និង អភិវឌ្ឍជំនាញដឹកនាំដែរឬទេ? បើមានមែន

- តើផ្តល់ឱកាសដោយរបៀបណា?

តើការគ្រប់គ្រងសាលា និងថ្នាក់រៀនបង្កបរិយាកាសសុវត្ថិភាព ថែទាំ និង មិនបង្កភាពខ្មាសអៀនសំរាប់ ទាំងក្មេងស្រី និង ក្មេងប្រុសដែរឬទេ? បើមានមែន តើបង្កើតបរិយាកាសបែបនោះដោយរបៀបណា? បើមិនមាន តើមានបញ្ហាអ្វី? ដោយប្រៀបធៀបរវាងការចុះគ្រប់គ្រង និង ត្រួតពិនិត្យដោយបុរស និង ស្ត្រី

- តើមានភាពខុសគ្នានៃចំនួនចុះត្រួតពិនិត្យ និង គុណភាពដែរឬទេ?

តើសាលារៀនមានផ្តល់ម្ហូបអាហារ និង អាហារថ្ងៃត្រង់ឱ្យសិស្ស

- ដែរឬទេ?

តើក្មេងស្រី និង ក្មេងប្រុសដើរទៅសាលាដោយមានសុវត្ថិភាពក្នុងភូមិស្រុករបស់គេដែរឬទេ? តើមានសេវាដឹកជញ្ជូនដែលមានសុវត្ថិភាព គួរឱ្យទុកចិត្ត និង តំលៃសមរម្យ ហើយ កុមារី និងកុមារាដែលរស់នៅឆ្ងាយពីសាលារៀន ប្រើប្រាស់សេវាដឹកជញ្ជូន នោះដែរឬទេ? តើក្នុងថ្នាក់រៀនមានកន្លែងទូលាយគ្រប់គ្រាន់សំរាប់កុមារី និង កុមារា សិក្សា និង កំសាន្តដែរឬទេ?

"សិស្សានុសិស្សគ្រប់ៗរូបគួរទទួលបានអ្វីៗទាំងអស់ដែលសាលារៀនផ្តល់ឱ្យ ប៉ុន្តែ ក្នុងជីវភាពប្រចាំថ្ងៃ សិស្សតែងមានតម្រូវការ និង ជំនាញរៀងៗខ្លួន ។ ឧទាហរណ៍ ក្មេងស្រីប្រហែលជាត្រូវទទួលខុសត្រូវ និង មានជំនាញពូកែធ្វើស្រែចំការ និង រៀបចំម្ហូបអាហារហើយក្មេងប្រុសប្រហែលជាមានជំនាញខាងមើលថែទាំងគោក្របី ។ ពាក្យយេនឌ័រជាសញ្ញាណសំគាល់នូវភាពខុសគ្នាដូចរៀបរាប់ខាងលើ ។ ប៉ុន្តែ ឆ្លើយតបនឹងតំរូវការដើម្បីមានជំនាញ យេនឌ័រជាក់លាក់នេះនៅក្នុងថ្នាក់រៀន អាចជាការមិនល្អ ព្រោះកត្តាទាំងនេះជំរុញឱ្យមានទំលាប់មិនល្អទាក់ទងនឹងយេនឌ័រ។ ក្មេងស្រីអាចរៀនអំពីការដាំស្ល ដាំបន្លែ ឬរាំរបាំបុរាណ ប៉ុន្តែ បើបង្រៀនជំនាញទាំងអស់នេះឱ្យតែក្មេងស្រីនោះគឺរឹតតែជំរុញឱ្យមានទំលាប់មិនល្អទាក់ទងនឹងយេនឌ័រថែមទៀត ហើយឧបសគ្គយេនឌ័រក៏មានមិនចប់ដែរ។ នៅពេលក្មេងស្រីនៅថ្ងៃនេះ ក្លាយជាស្ត្រីពេញវ័យនៅថ្ងៃក្រោយ ពួកគេនឹងត្រូវការជំនាញបច្ចេកវិទ្យា មេកានិក និងជំនាញគណិតវិទ្យា ដែលពីដើមមកចាត់ទុកជាជំនាញរបស់ប្រុស។ នៅពេលដែលក្មេង ប្រុសនៅថ្ងៃនេះក្លាយជាមនុស្សពេញវ័យ គេប្រហែលជាត្រូវការជំនាញធ្វើកិច្ចការផ្ទះ ដែលពីដើមមក ឪពុករបស់គេមិនដែលធ្វើសោះ។ បើសិន ជំនាញទាំងអស់របស់គេទនីមួយៗត្រូវបង្រៀនដល់សិស្សទាំងអស់ ពួកគេនឹងមានជំនាញសំរាប់បំពេញតំរូវការរបស់គេតាមដែលចាំបាច់។"លើសពីការចុះឈ្មោះចូលរៀន : កំរងសៀវភៅសំរាប់លើកកំពស់បទពិសោធន៍របស់កុមារីនៅថ្នាក់បឋមសិក្សា ABEL/USAID, 1996។

## ២. ខ្លឹមសារមេរៀន

- តើគុណភាពកម្មវិធីសិក្សាជាអ្វី? តើកម្មវិធីសិក្សាពាក់ព័ន្ធនឹងជីវភាពជាក់ស្តែងប្រចាំថ្ងៃបានកំរិតណា? តើកម្មវិធីសិក្សាមានបញ្ជ្រាបយេនឌ័រឬទេ? តើកម្មវិធីសិក្សាឱ្យតំលៃ និង បំពេញបន្ថែមចំពោះបំណិនជីវិត ដែលកុមារី និង កុមារា ទទួលបានពីក្រៅសាលាដែរឬទេ? ក្នុងស្ថានភាពប្រទេសជាច្រើន ជីវិតរបស់ក្មេងស្រី និង ក្មេងប្រុស មានភាពខុសគ្នាយ៉ាងខ្លាំង។[១]
- តើខ្លឹមសារមេរៀនមាននិយាយអំពីការអប់រំអំពីភេទសំរាប់ទាំងក្មេងប្រុស និង ក្មេងស្រីដែរឬទេ? តើខ្លឹមសារមេរៀនមានពត៌មានដើម្បីជួយឱ្យក្មេងស្រី និង ក្មេងប្រុសចេះការពារខ្លួនពីការជួញដូរ ពីការឆ្លងមេរោគអេដស៍ ពីការកេងប្រវ័ញ្ចពលកម្មកុមារ និង ពីការញៀនសុរា និង ថ្នាំញៀនដែរឬទេ?
- តើក្មេងប្រុស និង ក្មេងស្រីចូលរួមក្នុងសកម្មភាពដូចៗគ្នាដែរឬទេ ដូចជា កីឡា កំសាន្ត សិល្បៈ និង តន្ត្រី ។ល។?
- តើសៀវភៅសិក្សា និង សំភារៈសិក្សាមានគុណភាពដែរឬទេ? ហើយមានគ្រប់គ្រាន់សំរាប់សិស្សប្រើប្រាស់ដែរឬទេ? តើក្នុងសៀវភៅសិក្សា និង សំភារៈសិក្សាផ្សេងៗមានបង្ហាញនូវចំនួនស្មើគ្នារវាងស្ត្រី និង បុរសដែរឬទេ? តើរូបភាពក្មេងស្រី ក្មេងប្រុស ស្ត្រី និង បុរសបង្ហាញនៅក្នុងឯកសារសិក្សាទាំងនោះមានលក្ខណៈយ៉ាងដូចម្តេច? តើរូបគំនូរពេញរូបរាងរបស់ភេទទាំងពីរក្នុងសៀវសិក្សាមានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើសិស្ស ហើយបើសិស្សតូចៗ តើមានឥទ្ធិពលទៅលើពត៌មានអំពីខ្លួនគេ លក្ខណៈ និង ជំរើសអាជីពការងាររបស់គេយ៉ាងដូចម្តេច?[៣]

## ៣. ការសិក្សារបស់សិស្ស

- តើយុទ្ធសាស្ត្រសិក្សារបស់ក្មេងប្រុស និង ក្មេងស្រីមានអ្វីខ្លះ? តើមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច? បើខុសគ្នាមែន តើត្រូវប្រើវិធីសាស្ត្រគរុកោសល្យយ៉ាងដូចម្តេចដើម្បីដោះស្រាយបញ្ហានៃវិធីសាស្ត្ររៀនខុសគ្នារបស់ក្មេងប្រុស និង ក្មេងស្រី? តើកម្មវិធីសិក្សាមានលក្ខណៈទូលំទូលាយ ហើយអ្នកអប់រំមានចិត្តទូលំទូលាយយ៉ាងណាដែរ ក្នុងការដោះស្រាយវិធីរៀនខុសគ្នានេះ? តើគ្រូបង្រៀន និង អ្នកអប់រំបានទទួលការបណ្តុះបណ្តាលតាមវិធីណា ដើម្បីឱ្យគេយល់អំពីភាពខុសគ្នាទាំងនេះ?

---

៣ សូមអានឯកសារអំពីកែទម្រង់យេនឌ័រ ដើម្បីរៀបចំកម្មវិធីសិក្សា និង សៀវភៅសិក្សាដើម្បីចៀសវាងកុំឱ្យមានការរើសអើងយេនឌ័រនៅក្នុងឧបសម្ព័ន្ធ។

Guide.qxp 1/03/2005 4:10 PM Page 14

## ៤. សកម្មភាពសិក្សា

- តើគុណភាពនៃការបណ្តុះបណ្តាលគ្រូថ្មី បំប៉នគ្រូ និង គ្រូបំពេញបន្ថែមជាអ្វី? តើអ្នកគ្រូ ឬ អ្នកសំរបសំរួលស្ត្រីចូលរួមក្នុងវគ្គបណ្តុះបណ្តាលច្រើនដូចលោកគ្រូ ឬ អ្នកសំរបសំរួលបុរសដែរឬទេ? តើវគ្គបណ្តុះបណ្តាលទាំងនោះឆ្លើយតបនឹងតម្រូវការយេនឌ័រដែរឬទេ? តើការលើកកំពស់ការយល់ដឹងអំពីយេនឌ័រមានបញ្ចូលជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលគ្រូដែរឬទេ?
- តើមានគោលការណ៍ណែនាំ និងប្រព័ន្ធពិគ្រោះយោបល់ដែរឬទេ? តើកុមារីបានទទួលការណែនាំឱ្យចូលចិត្តមុខវិជ្ជាបច្ចេកទេស និង វិទ្យាសាស្ត្រ ឬ ក៏បង្អាក់កុំឱ្យក្មេងចូលចិត្តមុខវិជ្ជាទាំងនោះដែរឬទេ? តើក្មេងប្រុសច្រើនជំរុញឱ្យយកមុខវិជ្ជាអ្វីខ្លះ?តើថ្នាក់មុខវិជ្ជាគេហវិជ្ជា និង រោងជាង បង្រៀននៅម៉ោងជាមួយគ្នា ហើយក្មេងស្រីត្រូវដកចេញពីថ្នាក់រោងជាង ហើយក្មេងប្រុសត្រូវដកចេញពីថ្នាក់គេហវិជ្ជាដែរឬទេ? តើសិស្សទាំងអស់បានទទួលការណែនាំឱ្យរៀនបំណិនជីវិតទាំងអស់នេះដែរឬទេ? តើមានបំផុស និង គាំទ្រដល់ក្មេងប្រុស និង ក្មេងស្រី ឱ្យចំណាយពេលស្មើគ្នាក្នុងការរៀនកុំព្យូទ័រ និង រៀនជំនាញស្មើគ្នាក្នុងមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ មនុស្សវិទ្យា និង បច្ចេកទេសដែរឬទេ?

## ៥. លទ្ធផលសិក្សា

- តើមានប្រព័ន្ធអ្វីខ្លះសំរាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស? តើលទ្ធផលសិក្សារបស់សិស្សត្រូវបំបែកទៅតាមភេទ និងស្ថានភាពជនបទ ទីប្រជុំជនដែរឬទេ? តើលទ្ធផលសិក្សារបស់សិស្សស្រី និង សិស្សប្រុសតាមមុខវិជ្ជា និង តាមកំរិតសិក្សាមានខុសគ្នា ដែរឬទេ? បើមាន តើហេតុអ្វីបានជាមានបែបនេះ?
- តើមានភាពលំអៀងយេនឌ័រក្នុងការវាយតម្លៃរបស់គ្រូខ្លះ ឬ គ្រូទាំងអស់លើលទ្ធផលសិក្សារបស់សិស្សដែរឬទេ?

Guide.qxp 1/03/2005 4:10 PM Page 15

## ថ្នាក់រៀនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

ភាពលំអៀងយេនឌ័រអាចមាននៅក្នុងថ្នាក់រៀនក្នុងទំរង់ច្រើនបែប។ក្មេងប្រុសអាចទទួលការស្រលាញ់ចូលចិត្តច្រើនជាងក្មេងស្រី ឬក្មេងស្រីអាចទទួលការស្រលាញ់ចូលចិត្តច្រើនជាងក្មេងប្រុស។ភាពលំអៀងយេនឌ័រទាំងពីរនេះអាចមើលឃើញ ប៉ុន្តែមិនសូវច្បាស់។ ភាពលំអៀងយេនឌ័រអាចលុបបំបាត់ចោលដោយប្រើតារាងខាងក្រោម។

- **ការតុបតែងថ្នាក់រៀន** : ផ្ទាំងរូបភាព រូបថត ពាក្យស្លោក និង ទស្សនៈគំរូ ដែលបង្ហាញភាពស្មើគ្នារវាងបុរស និង ស្ត្រី ក្នុងឋានៈ និង តួនាទីដូចគ្នា ដូចជា វីរបុរស អ្នកដឹកនាំ និង អ្នកនិពន្ធ។ ការងាររបស់ក្មេងស្រី និង របស់ក្មេងប្រុស បទពិសោធន៍ជីវិត មានសរសេរនៅក្នុងកំរងរឿងរបស់សិស្ស សិល្បៈ និង ការតាំងពិព័រណ៍។
- **ការរៀបឱ្យសិស្សអង្គុយ** : គ្មានសិស្សប្រុស ឬសិស្សស្រីរៀបឱ្យអង្គុយដាច់ដោយឡែកពីគ្នា ដោយឱ្យសិស្សស្រីអង្គុយមុខ ហើយសិស្សប្រុសអង្គុយក្រោយទេ។ សិស្សស្រី និងសិស្សប្រុសស្មើគ្នាអង្គុយនៅមុខ ដូចនេះ គេអាចងាយស្តាប់ និងយកចិត្តទុកដាក់ស្តាប់គ្រូ អង្គុយក្បែរបង្អួចដែលមានពន្លឺ និងអង្គុយក្បែរកន្លែងកំដៅ។
- **រចនាសម្ព័ន្ធក្នុងថ្នាក់** : ទាំងសិស្សស្រី និង សិស្សប្រុសអាចធ្វើជាប្រធានថ្នាក់ ប្រធានក្រុមជាដើម។ ទាំងក្មេងស្រី និង ក្មេងប្រុស ចែកកិច្ចការថ្នាក់ និង កិច្ចការសាលាធ្វើស្មើៗគ្នា ។
- **សំភារៈសិក្សារបស់សិស្ស** : គ្រូត្រូវជួយសំរួលដល់ការបែងចែកសៀវភៅរៀន និង សំភារៈសិក្សាផ្សេងៗឱ្យសិស្ស ដូចនេះ ទាំងក្មេងប្រុសនិងក្មេងស្រី នឹងមានឱកាសរៀនស្មើៗគ្នា ។ មាតាបិតាត្រូវផ្តល់ និងផ្គត់ផ្គង់សំភារៈសិក្សាដល់កូនស្រី និង កូនប្រុសឱ្យបានស្មើៗគ្នា។ គ្រូត្រូវប្រើប្រាស់សមត្ថភាពជំនាញរបស់ខ្លួន ដើម្បីកាត់បន្ថយអារម្មណ៍ប្រកាន់មាន-ក្រ របស់សិស្សក្រីក្រ ដែលមិនមានសំភារៈសិក្សា និង សំលៀកបំពាក់ ដូចមិត្តរួមថ្នាក់របស់គេ។
- **ទីធ្លាកំសាន្ត** : ទាំងអ្នកគ្រូ និង លោកគ្រូ ត្រូវពិនិត្យ និង គ្រប់គ្រងទីធ្លាកំសាន្ត ហើយធ្វើយ៉ាងណាឱ្យសិស្សដែលមិនគោរពវិន័យ ដែលមិនចែកឱ្យសិស្សដទៃលេងជាមួយ ឬ សិស្សដែលរំខានដល់សិស្សដទៃ ចេះគោរពវិន័យ។ កន្លែងលេងកំសាន្ត សកម្មភាពកំសាន្ត និង សំភារៈ កំសាន្តត្រូវតែចែកឱ្យសិស្សស្រី និង សិស្សប្រុស លេងបានដូចៗគ្នា។
- **កម្មវិធីសិក្សា សៀវភៅសិក្សា និង សំភារៈរៀន/បង្រៀន** : ទាំងក្មេងប្រុស និង ក្មេងស្រីត្រូវឱ្យតម្លៃស្មើគ្នា ហើយរូបភាពក្មេងប្រុស និង ក្មេងស្រីត្រូវមាននៅក្នុងសំភារៈសិក្សាដូចៗគ្នា។
- **អន្តរទំនាក់ទំនងគ្រូ និង សិស្ស** : គ្រូត្រូវទំនាក់ទំនងខ្សែភ្នែក និងយកចិត្តទុកដាក់ជាមួយសិស្សស្រី និង សិស្សប្រុសទាំងអស់ អង្គុយមុខ និងអង្គុយក្រោយឱ្យបានស្មើៗគ្នា។ សិស្សប្រុស និង សិស្សស្រីត្រូវឆ្លើយនឹងសំណួរស្មើគ្នា ហើយគ្រូត្រូវឱ្យពេលវេលា និងជួយសិស្សប្រុសនិងសិស្សស្រីដែលជួបការលំបាកក្នុងការឆ្លើយនឹងសំណួរឱ្យបានស្មើៗគ្នា។គ្រូត្រូវអនុញ្ញាតឱ្យសិស្សប្រុស និង សិស្សស្រីបញ្ចេញទស្សនៈរបស់គេដោយខ្លួនឯង គិតគូរ និង វិភាគតាមសមត្ថភាពរបស់គេ។គ្រូត្រូវបង្រៀនឱ្យបានគ្រប់សិស្សក្នុងថ្នាក់ ហើយផ្តល់យោបល់ និង កែលំអកិច្ចការរបស់សិស្សឱ្យបានគ្រប់ៗគ្នា។
- **ភារកិច្ច និង ការទទួលខុសត្រូវ** : ភារកិច្ច និង ការទទួលខុសត្រូវដាក់ឱ្យសិស្សប្រុស និង សិស្សស្រីត្រូវដាក់តាមការលំបាករបស់សិស្ស ឬ តាមកំរិតនៃការទទួលខុសត្រូវរបស់សិស្ស។
- **វិន័យ** : វិន័យក្នុងថ្នាក់ និង ក្នុងសាលាត្រូវធ្វើយ៉ាងណាឱ្យសិស្សប្រុស និងសិស្សស្រីដឹងថា សិស្សទាំងអស់មានសុវត្ថិភាព មានតម្លៃ និងទទួលបានការការពារកុំឱ្យមានការបំផ្លាញកិត្តិយសផ្លូវភេទ ឬ កុំឱ្យមានហិង្សា និង កុំឱ្យមានការខ្លាចរៀន។ សិស្សទាំងអស់ត្រូវដឹងថា រំលោភសិទ្ធិអ្នកដទៃ ឬ ធ្វើបាបអ្នកដទៃ មិនត្រូវបានអនុញ្ញាតឱ្យកើតមាននៅក្នុងសាលា។ ទាំងអ្នកគ្រូ និង លោកគ្រូត្រូវប្រើគ្រប់វិន័យសមស្របទាំងអស់ ប៉ុន្តែ មិនត្រូវដាក់ទណ្ឌកម្មដល់សិស្សឡើយ។
- **ភាសា** : គ្រូ សិស្ស និង សៀវភៅត្រូវប្រើភាសា ដែលមិនមានលំអៀងយេនឌ័រ។
- **ការប្រើប្រាស់សំភារៈ និង ឧបករណ៍រៀន និង បង្រៀន** : ចែកឱ្យសិស្សស្រី និង សិស្សប្រុសប្រើប្រាស់សៀវភៅ កុំព្យូទ័រ ម៉ាស៊ីនគិតលេខ សំភារៈកីឡា ឧបករណ៍សាលពិសោធន៍ និង សំភារៈវិជ្ជាជីវៈឱ្យបានស្មើៗគ្នា ។

ដើម្បីឆ្លើយនឹងសំណួរទាំងនេះ ត្រូវចាំថា ក្រសួងអប់រំភាគច្រើនមានប្រព័ន្ធ គ្រប់គ្រងព័ត៌មានអប់រំជាតិ (EMIS) ដែលមានព័ត៌មានអំពីចំនួនគ្រូ និង អ្នកគ្រប់គ្រង ដោយរៀបចំតាមភេទ កំរិតអប់រំ កំណត់ហេតុតំឡើងតួនាទី និង ឋានៈ ។ល។ ប៉ុន្តែ ព័ត៌មានទាំងអស់មិនទាន់បានវិភាគឱ្យបានល្អិតល្អន់ដើម្បីរកឱ្យឃើញគម្លាតយេនឌ័រឱ្យច្បាស់លាស់នៅឡើយទេ ។ សំណួរពិបាកឆ្លើយជាងនេះច្រើនទាក់ទងនឹង គុណភាព បរិយាកាសសិក្សា កម្មវិធីសិក្សា និង សកម្មភាព រៀន-បង្រៀននៅក្នុងថ្នាក់ ។ ការស្រាវជ្រាវរកទិន្នន័យគុណវិស័យត្រូវធ្វើឱ្យបានដើម្បីសិក្សា និង វិភាគលើបញ្ហាជាច្រើន ។ ប៉ុន្តែជួនកាល លទ្ធផលបានពីការស្រាវជ្រាវមានជានិក្ខេបបទដែលមិនទាន់បោះពុម្ព អត្ថបទក្នុងបណ្ណាល័យនៃស្ថាប័នស្រាវជ្រាវអប់រំ ឬ មាននៅតាមបណ្តាអង្គការក្រៅរដ្ឋាភិបាលនានា។ ឯកសារនានាត្រូវតែចងក្រង និង ចំណុចខ្វះខាត និង គម្លាត ត្រូវតែវិភាគរកឱ្យឃើញ ហើយ ផែនការត្រូវធ្វើឱ្យបានដើម្បីបំពេញកង្វះខាតព័ត៌មាន។

ដូចបាននិយាយខាងលើ ផែនការ និង យុទ្ធសាស្ត្រសំរាប់លុបបំបាត់គម្លាតព័ត៌មាន និង ស្រាវជ្រាវជាផ្នែកមួយនៃការអនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នាដោយឈរលើទស្សនៈពិនិត្យ និងកែលំអយុទ្ធសាស្ត្រក្នុងទ្រង់ទ្រាយធំ បើលទ្ធផលស្រាវជ្រាវតំរូវឱ្យធ្វើបែបនេះ។

## គ. គ្រប់គ្រង

ការគ្រប់គ្រងជាទស្សនៈសំខាន់ ដែលត្រូវពិចារណា។ សំណួរពាក់ព័ន្ធមាន :

■ **តើស្ត្រី និង បុរស ដែលកាន់តួនាទីនៅគ្រប់កំរិតក្នុងប្រព័ន្ធអប់រំមានចំនួនស្មើគ្នាដែរឬទេ?** តើគេមានតួនាទីជាអ្វី នៅក្នុងការគ្រប់គ្រងប្រព័ន្ធអប់រំនៅគ្រប់កំរិត? តើបុរស និង ស្ត្រីមានឱកាសដូចគ្នាក្នុងការអភិវឌ្ឍជំនាញ និង វិជ្ជាជីវៈដែរឬទេ? តើគេទទួលបានការលើកទឹកចិត្តសមស្រប និងប្រាក់លើកទឹកចិត្តឱ្យទៅចូលរៀនក្នុងកម្មវិធីអភិវឌ្ឍជំនាញដែរឬទេ? តើមានវិធានការសំរាប់ជួយសំរួលកិច្ចការផ្ទះរបស់ស្ត្រីដើម្បីឱ្យស្ត្រីមានពេលវេលាចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានាដែរឬទេ? នៅប្រទេសដែលមានគ្រូស្រីភាគច្រើន ស្ត្រីនៅតែមានចំនួនតិចកាន់តួនាទីជានាយកសាលា នោះមិននិយាយអំពី ប្រធានមន្ទីរអប់រំស្រុក ឬ ខេត្តឡើយ។ តើមានគោលនយោបាយច្បាស់លាស់ណាមួយដើម្បីផ្លាស់ប្តូរស្ថានភាពបែបនេះដែរឬទេ? នៅប្រទេសជាច្រើន អតុល្យភាពយេនឌ័រក្នុងកំលាំងជាគ្រូបង្រៀន ទាំងនៅបឋមសិក្សា និង មធ្យមសិក្សាមានអត្រាខ្ពស់ គឺមានភេទមួយតិច ហើយមួយទៀតច្រើន។ គ្មានករណីណាមួយល្អប្រសើរបំផុតនោះទេ។ ទាំងក្មេងប្រុស និង ក្មេងស្រីត្រូវការ

រៀនពីតួនាទីគំរូល្អពីគ្រូ ដូចនេះ ត្រូវធ្វើយ៉ាងឱ្យមានតុល្យភាពប្រហែល ៤០-៦០ ភាគរយ។ ដោយសារបញ្ហាសន្តិសុខដែលធម្មតាជាបញ្ហារបស់ក្មេងស្រី សំខាន់ជាងក្មេងប្រុស ដូចនេះ ករណីដែលសាលារៀនមួយមានអ្នកគ្រូមួយនាក់ គឺជាតំរូវការបន្ទាន់ និង ចាំបាច់។

- **តើប្រាក់ខែ និង ការឧបត្ថម្ភផ្សេងៗទៀត គិតទាំងផ្ទះស្នាក់នៅ ស្មើគ្នា និង សមស្រប សំរាប់ទាំងអ្នកគ្រូ និង គ្រូប្រុសដែរឬទេ?** តើមានប្រព័ន្ធ ឬ ច្បាប់ណាដែលអាចធានាថា ប្រាក់ខែ និង ការឧបត្ថម្ភនានា គិតទាំងផ្ទះស្នាក់នៅ ស្មើគ្នា និង សមស្រប សំរាប់បុរស និង ស្ត្រីដែរឬទេ?

- **តើមានទំរង់ការច្បាប់ណាមួយសំរាប់ជួយការពារនៅពេលអចត្តមានអ្នកដឹកនាំសាលា ឬ គ្រូបង្រៀនដែរឬទេ?** តើទំរង់ការច្បាប់នោះមានការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធ (គិតទាំងមាតាបិតាសិស្ស និង សហគមន៍) ដែរឬទេ?

- **តើក្រសួងអប់រំមានគោលនយោបាយណាមួយអាចដោះស្រាយបញ្ហាបំផ្លាញកិត្តិយសផ្លូវភេទនៅសាលារៀន និង នៅក្នុងប្រព័ន្ធដឹកនាំអប់រំនៅគ្រប់កំរិតដែរឬទេ?**

**ដើម្បីឆ្លើយនឹងសំណួរទាំងនេះ** ការបែងចែកតាមប្រភេទ និង វិភាគលើស្ថិតិដែលមានស្រាប់ ត្រូវតែអនុវត្តឱ្យបាន ហើយ ការអង្កេតស្រាវជ្រាវអំពីឋានៈ និង តួនាទីរបស់ស្ត្រី ក្នុងតំណែងគ្រប់គ្រងប្រព័ន្ធអប់រំក៏ត្រូវអនុវត្តឱ្យបានដែរ។

## ២. ថែទាំ និង អប់រំកុមារតូច

គោលដៅទីមួយរបស់ក្របខណ្ឌដាកា គឺពង្រីកការថែទាំ និង អប់រំកុមារតូច ។ កម្មវិធីកុមារតូចមានតួនាទីសំខាន់ក្នុងការរៀបចំឱ្យកុមារា និង កុមារីតូចៗត្រៀមខ្លួនជាស្រេច ទាំងរូបរាងកាយ និង បញ្ញា ដើម្បីចូលរៀននៅថ្នាក់បឋមសិក្សា។ បើរៀបចំយុទ្ធសាស្ត្រលំអិតដើម្បីសំរេចគោលដៅក្របខណ្ឌដាកា គោលដៅ ២ គោលដៅ ៤ គោលដៅ ៥ ចាំបាច់ត្រូវពិចារណាដល់តួនាទី និង សារប្រយោជន៍នៃកម្មវិធីថែទាំ និង អប់រំកុមារតូចក្នុងយុទ្ធសាស្ត្រទាំងនោះ។

តាមទស្សនៈរបស់ស្រីៗ កត្តានេះមានសារសំខាន់ជាពិសេស។ ការថែទាំប្អូនតូចៗ ជាភារកិច្ចទីមួយ និង សំខាន់បំផុត ដែលជាកត្តាទាញឱ្យក្មេងស្រីចេញក្រៅសាលា ។ នៅប្រទេសជាច្រើន ក្មេងស្រីបោះបង់ចោលសាលា ហើយចូលរៀនមិនសូវទៀងទាត់ដោយសារភារកិច្ចមើលថែទាំងប្អូនតូច ។ ពង្រីក

កម្មវិធីថែទាំ និង អប់រំកុមារតូចជាយុទ្ធសាស្ត្រមួយដើម្បី**បង្កើនអត្រាចូលរៀនរបស់សិស្សស្រី** ។ នៅប្រទេសខ្លះ ការចុះឈ្មោះចូលរៀនរបស់កុមារក្រោមអាយុចូលរៀននៅថ្នាក់ទីមួយ ក៏ជាដើមហេតុនៃការបោះបង់ចោលសាលា ត្រួតថ្នាក់ និង រៀនធ្លាក់ផងដែរ។ ក្នុងន័យនេះ កម្មវិធីថែទាំ និង អប់រំ កុមារតូចៗមានតួនាទីសំខាន់ក្នុងការរួមចំណែក **លើកកំពស់ប្រសិទ្ធភាព**ប្រព័ន្ធអប់រំបឋមសិក្សា គឺគ្រាន់តែផ្តល់នូវកន្លែងមួយ សំរាប់កុមារតូចប៉ុណ្ណោះ។

ក្នុងករណីជាច្រើន វត្តមាននៃបរិក្ខាថែទាំកុមារតូច ជាប្រការមួយអាចជួយឱ្យ**ស្ត្រីចូលរួម** ក្នុងកម្មវិធី អក្ខរកម្ម ឬ អប់រំក្រៅប្រព័ន្ធ ដូចនេះ ស្ត្រីអាចមានពេលវេលាសំរាប់រកប្រាក់ចំណូល ឬ ទៅធ្វើការ ហើយអាចចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍ និង ការងារនយោបាយបានយ៉ាងសកម្ម។

ការពិតដែលគេស្គាល់ជាទូទៅថា ទំនាក់ទំនងរបស់កុមារតូចក្នុងសង្គម កុមារចាប់ផ្តើមតាំងពីវ័យក្មេងមកម៉្លេះ ដែលអ្នកខ្លះនិយាយថា ចាប់ផ្តើមតាំងពីកំណើត ឬ តាំងពីមិនទាន់កើត ។ ក្នុងវប្បធម៌សង្គមភាគច្រើន ទំនាក់ទំនងសង្គម ក្នុងតួនាទីយេនឌ័រណាមួយមិនអាចទទួលយកបាន ។ ក្នុងប្រពៃណីភាគច្រើន ក្មេងស្រី និង ក្មេងប្រុសទទួលការយកចិត្តទុកដាក់ខុសគ្នាតាំងពីកំណើតមកម៉្លេះ។ ទីមួយគឺ ការផ្តល់ចំណីអាហារ និងថែទាំបានល្អជាងភេទមួយទៀតទទួលការថែទាំសុខភាពបានល្អប្រសើរជាង ហើយលើកទឹកចិត្តខុសគ្នាតាំងពីមុនចូលសាលាមកម៉្លេះ។ ភេទទាំងពីរ ជាការពិត ត្រូវមានភារកិច្ចយេនឌ័រជាច្រើនក្នុងគ្រួសារ។ តាមប្រពៃណីពីបុរាណមក កម្មវិធីកុមារតូច អាចជំរុញបន្តឱ្យមានជំនឿ និង ទំលាប់មិនល្អអំពីយេនឌ័រតាំងពីក្នុងផ្ទះ និង ក្នុងសហគមន៍ ។ ម្យ៉ាងវិញទៀត កម្មវិធីកុមារតូច អាចរួមចំណែកលុបបំបាត់លំអៀងយេនឌ័រ បើកម្មវិធីនេះត្រូវបានរៀបចំយ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើយ៉ាងណាឱ្យមានយុត្តិធម៌សំរាប់ទាំងកុមារា និង កុមារី។

អប់រំកុមារតូចក៏ផ្តល់ឱកាសឱ្យបុរស និង ស្ត្រី ក្លាយជាគ្រូមត្តេយ្យផងដែរ។ តួនាទីនេះធំធេងជាងតួនាទីដែលគ្រាន់តែមើលថែទាំកុមារ ហើយ តួនាទីនេះក៏ជួយអភិវឌ្ឍសក្តានុភាពជាមនុស្សរបស់កុមារា និង កុមារីតូចផងដែរ ក្នុងវ័យដែលកុមារត្រូវការពត៌មានច្រើនបំផុត។

Guide.qxp 1/03/2005 4:10 PM Page 19

## ៣ យុវវ័យ

គោលដៅរួមគឺធ្វើកំណែទំរង់សាលារៀន ធ្វើយ៉ាងណាឱ្យសាលារៀនមានសមត្ថភាពទទួលកុមារទាំងអស់ ដោយមិនប្រកាន់ភេទ ជនជាតិ ឋានៈ សង្គម និង សមត្ថភាពឡើយ ។ ប៉ុន្តែ ក្នុងរយៈពេលខ្លី វិធីសាស្ត្រអប់រំក្រៅប្រព័ន្ធជាកម្មវិធី ដែលនៅតែត្រូវការជាងគេ ក្នុងការផ្តល់ឱកាសដល់យុវវ័យ ដែលមិនបានចូលសាលា ។ កម្មវិធីអប់រំក្រៅប្រព័ន្ធត្រូវតែរៀបចំសំរាប់កុមារី ដែលត្រូវបង្ខំឱ្យបោះបង់ ចោលការសិក្សាតាំងពីថ្នាក់ទាប ដើម្បីឱ្យកុមារីទាំងនោះទទួលបានអក្ខរកម្មវិជ្ជាជីវៈ ឬ សំរាប់កុមារី ដែលមិនដែលមានឱកាសចូលសាលាតាំងពីមុនមក ដើម្បីឱ្យគេមានជំនាញ និង បំណិនជីវិតសំរាប់ជីវភាពរស់នៅរបស់គេ ។ នៅអាស៊ី កុមារាត្រូវដកចេញពីសាលាឱ្យឈប់រៀនដើម្បីឱ្យមើលថែទាំគោក្របី ធ្វើការជាកម្មករនៅតាមផ្សារ និង ធ្វើការក្នុងស្ថានភាពពលកម្មកុមារ ។ កុមារីត្រូវបញ្ឈប់ពីសាលាដើម្បីឱ្យមើលថែទាំប្អូនតូចៗ មនុស្សចាស់ និង អ្នកជំងឺ ។ ចំនួនកុមារីដែលត្រូវបញ្ឈប់ពីសាលាដើម្បីឱ្យទៅ បេះកប្បាស ឬធ្វើស្រែចំការ ឬ ត្រូវគេបោកយកទៅលក់ឱ្យបំរើផ្លូវភេទមានការកើនឡើង ។ កុមារទាំងនេះគួរទទួលបានការអប់រំដែលផ្តល់នូវសមត្ថភាព និង សិទ្ធិអំណាចក្នុងការសំរេចចិត្តឱ្យបានត្រឹមត្រូវ និង ដើម្បីការពារខ្លួនកុំឱ្យ មានការរំលោភបំពានសិទ្ធិ និង ដើម្បីរស់នៅក្នុងសង្គមប្រកបដោយជីវភាពល្អប្រសើរ ។[៤]

ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ ដោយសារមានកុមារីត្រូវបង្ខំឱ្យបោះបង់ចោលសាលាច្រើនជាងក្មេងប្រុស អង្គការក្រៅរដ្ឋាភិបាល និង រដ្ឋាភិបាលមានបទពិសោធន៍អនុវត្តកម្មវិធីជាមួយក្មេងស្រីវ័យជំទង់[៥]បានជោគជ័យ ។ ដូចនេះ បច្ចុប្បន្ន យើងមានបទពិសោធន៍ជាច្រើន និង ថ្មីៗ ព្រមទាំងមេរៀនល្អៗ យកទៅបង្ហាញអ្នកអប់រំឱ្យយល់ច្បាស់អំពីបញ្ហានេះ[៦] ។ ភារកិច្ចចំពោះមុខដែលត្រូវបំពេញឱ្យបានក្នុងរយៈពេល ១០ ឆ្នាំទៅមុខទៀត ដើម្បីអនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នា គឺត្រូវបង្កើតយុទ្ធសាស្ត្រដើម្បីផ្តល់នូវកម្មវិធីដែលមានគុណភាពក្នុង **ទ្រង់ទ្រាយធំ និង ជាលក្ខណៈប្រព័ន្ធ** ច្បាស់លាស់ ។

---

៤ ត្រូវការព័ត៌មានបន្ថែម សូមអានគេហទំព័ររបស់ UNESCO/UNFPA ស្តីពីសុខភាពបន្តពូជ និង សុខភាពផ្លូវភេទរបស់យុវវ័យតាម www.unescobkk.org/ps/ach-web/index.shtml.

៥ ត្រូវការព័ត៌មានបន្ថែមសូមអាន : Mathur, R., Taking Flights. Adolescent Girls Camps, UNESCO, Bangkok, 2001.The Women's Literacy and Basic Skills Training Project in Lao PDR: Innovations for Youth, (Vol.2), UNESCO, Paris, 1999.

៦ Leveling the Playing Field. Giving Girls an Equal Chance for Basic Education: Three Country Efforts, Economic Development Institute of the World Bank (no date) Orzen, P.F., The Urban and Rural Fellowship School Experiments in Pakistan: Design, Evaluation and Sustainability, World Bank, Washington DC, 2000. http://www.girlseducation.org
Bangladesh: Female secondary school assistance, World Bank, Washington DC, 2000. http://www.girlseducation.org

គ្មានកិច្ចសហការជិតស្និទ្ធរវាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និង អ្នកស្រាវជ្រាវលើវិស័យនេះ យើងនឹងមិនអាចសំរេចគោលដៅក្រុងដាកាបានទេ។ ភារកិច្ចនេះច្រើនជួបការលំបាកនៅពេលដែលទំលាក់ភារកិច្ចនេះឱ្យទៅផ្នែកក្រៅប្រព័ន្ធ។ លើសនេះទៀត ភារកិច្ចនេះប្រហែលជាជួបការលំបាកក្នុងការប៉ាន់ស្មានតម្រូវការជាចំនួនជាក់ស្តែងគិតជាតួលេខ និង បរិមាណធនធាន ដែលត្រូវប្រើដើម្បីបំពេញតម្រូវការទាំងនេះក្នុងរយៈពេលប្រមាណ ១០ ទៅ ១៥ ឆ្នាំខាងមុខទៀត ។ ប៉ុន្តែ រដ្ឋាភិបាលអាចជួយសំរួលឱ្យមានការជឿនលឿនលើភារកិច្ចនេះបាន ដោយគ្រាន់តែបង្កើតក្រុមខណ្ឌសកម្មភាពផ្នែកច្បាប់ និង **បង្កើតបរិយាកាសនយោបាយ** ដែលជួយជំរុញឱ្យស្ថាប័ននានារបស់រដ្ឋាភិបាលសហការជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការតាមសហគមន៍ ដើម្បីអនុវត្តកម្មវិធី និង គំរោងរបស់គេលើផ្នែកនេះឱ្យមានប្រសិទ្ធភាព។ រដ្ឋាភិបាលអាចគាំទ្រ និងផ្សព្វផ្សាយឯកសារស្រាវជ្រាវផលិតឯកសារបណ្តុះបណ្តាល តាមដានកម្មវិធី ផ្តល់វិញ្ញាបនប័ត្រ និង ជួយសំរួលឱ្យអ្នកសិក្សាបានចូលក្នុងប្រព័ន្ធផ្លូវការរបស់រដ្ឋវិញ។

## អប់រំក្រៅប្រព័ន្ធ និង បណ្តុះបណ្តាលអក្ខរកម្មសំរាប់មនុស្សពេញវ័យ[៧]

សំរេចគោលដៅទី៤ របស់ក្រុងដាកា ជាដំបូងហើយមិនអាចខ្វះបាន គឺត្រូវជំរុញឱ្យបង្កើនហិរញ្ញវត្ថុសំរាប់កម្មវិធីនេះ ហើយពង្រីកកម្មវិធីនេះឱ្យទូលំទូលាយថែមទៀត។ លើសនេះទៀត កម្មវិធីនេះក៏ត្រូវការកិច្ចប្រឹងប្រែងដោយមិនខ្លាយឡើយហត់ទាំងអស់គ្នា ដើម្បីលើក **កំរិតគុណភាព** នៃកម្មវិធីនេះ និង **ភាពពាក់ព័ន្ធ** របស់វាទៅនឹងជីវភាពពិតរបស់ប្រជាជន។

នៅប្រទេសជាច្រើន អក្ខរកម្មស្ត្រីមានចំនួនតិចជាងបុរស។ ការខិតខំប្រឹងប្រែងដើម្បីបង្កើនអក្ខរកម្មមនុស្សពេញវ័យនឹងមិនអាចសំរេចជោគជ័យបានទេ បើមិនបំបាត់ឧបសគ្គរារាំងស្ត្រីមិនឱ្យចូលរួមក្នុងកម្មវិធីអក្ខរកម្ម។

ស្ទើរតែក្មេងស្រីមិនមានពេលវេលាគ្រប់គ្រាន់សំរាប់ការសិក្សានៅសាលាផង ដូចនេះស្ត្រីពេញវ័យរឹតតែគ្មានពេលវេលាសំរាប់កម្មវិធីអក្ខរកម្មថែមទៀត។ ស្ត្រីពេញវ័យមានការងារច្រើនតំរូវឱ្យគាត់ធ្វើក្នុងពេលវេលាដែលគាត់មានបាត់បង់នូវចិត្តចង់របស់គាត់ ហើយចង់ឃើញលទ្ធផលជាក់ស្តែងភ្លាម និង ចង់ឃើញការរីកចំរើនសំរាប់ជីវិតភ្លាមៗ ដើម្បីបំពេញចំណង់របស់ខ្លួន។ កត្តាទាំងនេះមានសារសំខាន់ និង ត្រូវចងចាំ ហើយត្រូវដោះស្រាយឱ្យបាន នៅពេលរៀបចំកម្មវិធីអក្ខរកម្ម។ បើកម្មវិធីផ្តល់នូវអក្ខរភាព និង បំណិនជីវិត

៧ សំរាប់ព័ត៌មានលំអិតអំពីសមភាពយេនឌ័រក្នុងការអប់រំក្រៅប្រព័ន្ធ សូមអានអប់រំសំរាប់ទាំងអស់គ្នា: Gender Equality in Non-formal Basic Education: A Strategic Framework, UNESCO, 2001.

ដល់ស្រ្តីសំរាប់យកទៅប្រើដើម្បីលើកកំពស់គំរិតជីវភាពរស់នៅឱ្យបានល្អប្រសើរ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ខ្លួន **ស្រ្តីក៏ត្រូវការធនធាន សំរាប់ផ្តល់ សិទ្ធិ និង អំណាច** ផងដែរ។ កម្មវិធីអក្ខរកម្មគួរបំពេញតម្រូវការជាយុទ្ធសាស្រ្ត ដើម្បីធ្វើយ៉ាងណាឱ្យស្រ្តីមានសមត្ថភាពចូលរួមក្នុងការសំរេចចិត្តក្នុងគ្រួសារ និង ក្នុងសហគមន៍ ហើយកម្មវិធីក៏គួរផ្តល់ឱ្យស្រ្តីនូវព័ត៌មានអំពី សិទ្ធិស្របច្បាប់របស់ស្រ្តីផងដែរ។

ដោយសារមានកិច្ចការចាំបាច់ជាច្រើនដែលត្រូវធ្វើ ដូចនេះ ស្រ្តីភាគច្រើនបោះបង់ចោលការសិក្សាពីកម្មវិធីអក្ខរកម្មមនុស្សចាស់ ឬឈប់ចូលរៀនហួតមុននឹងរៀនចប់ថ្នាក់អក្ខរកម្ម។ ដោយសារតែរៀនបានតិចតួចពេក ហើយគ្មានសៀវភៅអានបន្តសំរាប់ទាំងថ្នាក់ដំបូង និង ថ្នាក់មធ្យម ក្រោយពីឈប់រៀន(ជាពិសេសនៅជនបទ)ស្រ្តីបានក្លាយជាអនក្ខរជនយ៉ាងច្រើន។ តួលេខអក្ខរកម្មពិតប្រាកដ តែងតែតិចជាងស្ថិតិផ្លូវការរបស់រដ្ឋាភិបាល ហើយគំរូវការវិធានការជាក់លាក់សំរាប់បន្តអក្ខរកម្មតែងតែច្រើនជាងការស្មាន។

តាមកម្មវិធីសំរាប់ក្មេងស្រីវ័យជំទង់ (យុវវ័យ) មានកម្មវិធីជោគជ័យជាច្រើនជាពិសេស អនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល និងអង្គការតាមសហគមន៍ (CBOs) ។ ដូចនេះ ភារកិច្ចចំបងចំពោះមុខគឺ ធ្វើយ៉ាងណាធានាឱ្យមានការចែករំលែកមេរៀន និង បទពិសោធន៍ល្អៗទាំងនេះ នៅថ្នាក់ជាតិ តំបន់ និង នៅភាគអន្តរជាតិ ហើយត្រូវរកមធ្យោបាយ និង វិធានការសមស្របដើម្បីពង្រីកគម្រោងតូចៗ ដែលទទួលបានជោគជ័យឱ្យទៅជាកម្មវិធីធំដែលទទួលជោគជ័យទាំងបរិមាណ និង គុណភាព។

រដ្ឋាភិបាលត្រូវបង្កើតក្របខណ្ឌច្បាប់មួយដើម្បីសំរួលដល់ការងាររបស់វិស័យឯកជន និង សហគមន៍ ក្នុងគោលបំណងធានាឱ្យមានការសំរបសំរួលចែករំលែកព័ត៌មានគ្នា ហើយ លើកកំពស់ការប្រើធនធានសេដ្ឋកិច្ច និងធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។

## អេដស៍ យេនឌ័រ និង អប់រំ

ការរីករាលដាលនៃការឆ្លងមេរោគអេដស៍មានឆ្លងដល់កុមារ ជះឥទ្ធិពលអាក្រក់ដល់កុមារ យុវវ័យ និងមនុស្សពេញវ័យ ។ នេះជាមូលហេតុមួយ ដែលបញ្ជាក់ថា ការអប់រំទទួលផលអាក្រក់ពីការរីករាលដាលនៃមេរោគនេះ ប៉ុន្តែ អប់រំក៏មានតួនាទីដ៏សំខាន់មួយដើម្បីការពារ និង គាំទ្រដល់មនុស្សដែលមានផ្ទុកមេរោគអេដស៍។ ទំនាក់ទំនងរវាងអប់រំ មេរោគអេដស៍/ជំងឺអេដស៍ និង យេនឌ័រត្រូវតែសិក្សាវិភាគ និង ស្វែងយល់ឱ្យច្បាស់ដើម្បីឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ និង លុបបំបាត់ការឆ្លងរាលដាលនៃមេរោគអេដស៍នេះ។

កាត់បន្ថយការគំរាមកំហែងអេដស៍ទៅលើបុគ្គលម្នាក់ៗ និង សហគមន៍ លើកកំពស់សមភាពយេនឌ័រ និងធ្វើឱ្យប្រសើរនូវការចូលរៀន ហើយការសំរេចជោគជ័យទាំងបីផ្នែកនេះជាការប្រសើរបំផុត ព្រោះផ្នែកនីមួយៗនេះអាចជួយបំពេញឱ្យគ្នាទៅវិញទៅមក។

វិសមភាពគិតជាតួលេខក្នុងការទទួលការអប់រំ និង រក្សាកុមារា និង កុមារីឱ្យនៅរៀនបានយូរអង្វែង ការលុបបំបាត់ទំលាប់រើសអើងយេនឌ័រនៅក្នុងសៀវភៅសិក្សា និង កម្មវិធីសិក្សា សកម្មភាពរៀន-បង្រៀន ការចូលរួម និង ការសំរេចលទ្ធផលរៀនសូត្រ ព្រមទាំងវិសមភាពយេនឌ័រក្នុងការគ្រប់គ្រងការងារអប់រំ មានប្រយោជន៍ត្រង់ថា ការអប់រំមានតួនាទីដោះស្រាយការគំរាមកំហែងនៃការរីករាលដាលនៃមេរោគអេដស៍។

លើសនេះទៀត បញ្ហាកង្វះគ្រូបង្រៀន ព្រោះគ្រូស្លាប់ដោយសារមេរោគអេដស៍/ជំងឺអេដស៍ និង វិបត្តិផ្ទាល់របស់គ្រូបង្រៀន ដោយសារមេរោគនេះគុណភាពអប់រំក៏អាចធ្លាក់ចុះដែរ។ ហេតុផលនេះ ពិតជាជះឥទ្ធិពលអាក្រក់ដល់កុមារា និង កុមារីជាមិនខាន។

ក្មេងស្រីទទួលផលវិបាកពីមេរោគអេដស៍/ជំងឺអេដស៍ខ្លាំងជាងក្មេងប្រុស បើគិតតាមលក្ខណៈសារីរាង្គកាយ តាមកត្តាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ ក្មេងស្រីដែលរងការឆ្លងមេរោគអេដស៍ ច្រើនទទួលការមាក់ងាយ រើសអើងច្រើនជាងក្មេងប្រុស ហើយភាគច្រើន ងាយបោះបង់ចោលសាលា។ ចំណែកក្មេងប្រុស និង បុរសច្រើនព្រួយបារម្ភ អំពីទំលាប់សង្គម ឬ ពីមិត្តភក្តិ អំពីរឿងរួមភេទដោយសុវត្ថិភាព។ការប្រព្រឹត្តិ គ្រឿងញៀន និង សុរា និង បំលាស់លំនៅដោយសារហេតុផលការងារ រឹតតែ ជំរុញឱ្យប្រឈមមុខនឹងគ្រោះថ្នាក់ថែមទៀត ។ កត្តាទាំងនេះ ត្រូវតែយកទៅពិចារណាឱ្យច្បាស់លាស់នៅពេលរៀបចំផែនការសំរាប់វិស័យអប់រំ ដើម្បីដោះស្រាយបញ្ហាសមភាពយេនឌ័រ និង ទប់ស្កាត់ការឆ្លងនៃមេរោគអេដស៍។

អន្តរាគមន៍វិស័យទាំងបី មេរោគអេដស៍/ជំងឺអេដស៍ សមភាពយេនឌ័រ និង អប់រំបានក្នុងពេលតែមួយ នឹងជួយលើកកំពស់ និង ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលជោគជ័យនៃវិស័យនីមួយៗយ៉ាងពិតប្រាកដ ។ ដូចនេះ ត្រូវយកចិត្តទុកដាក់លើកត្តាសំខាន់ៗដូចខាងក្រោម:

- ឱ្យក្មេងស្រីចូលសាលារៀនរហូតឱ្យគេរៀនចប់មធ្យមសិក្សា ហើយ ទប់ស្កាត់កុំឱ្យក្មេងប្រុសបោះបង់ចោលសាលា
- លើកកំពស់សុវត្ថិភាព ទាំងក្នុង និង ក្រៅសាលា ជាពិសេស ផ្តល់ការស្នាក់នៅ និង ហូបចុកនៅក្នុងសាលាឱ្យទាំងក្មេងប្រុសនិងក្មេងស្រី
- រៀបចំកម្មវិធីសិក្សាអំពីភេទ និង សុខភាពបន្តពូជឱ្យបានល្អ និង មានគុណភាព ហើយបង្រៀនសិស្សឱ្យស្របតាមលក្ខណៈប្រសិទ្ធភាពយេនឌ័រ

Guide.qxp 1/03/2005 4:10 PM Page 23

- ផ្តល់ចំណេះដឹង និង សិទ្ធិអំណាចដល់ទាំងក្មេងស្រី និងក្មេងប្រុសដើម្បីឱ្យគេមានជំរើសច្រើននៅក្នុងសង្គម និង មានសមត្ថភាពចូលរួមក្នុងដំណើរការសំរេចចិត្តផ្សេងៗ
- លើកកំពស់ស្វ័យម្ចាស់ការដោយទទួលខុសត្រូវ និង ជំនាញចរចាដល់ទាំងក្មេងប្រុស និង ក្មេងស្រី ដើម្បីឱ្យគេមានសមត្ថភាពគ្រប់គ្រង ខ្លួនឯង និង ជីវិតផ្លូវភេទដោយខ្លួនឯង។
- បណ្តុះបណ្តាលគ្រូ ដើម្បីឱ្យគ្រូមានសមត្ថភាពរកវិធីផ្សេងៗសមស្រប ដើម្បីលុបបំបាត់ការរើសអើងយេនឌ័រ ហើយ អាចដោះស្រាយការរើសអើងបាននៅពេលគ្រូជួបប្រទះ។
- លើកកំពស់សកម្មភាពទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ឱ្យមានប្រសិទ្ធភាពសំរាប់គ្រូបង្រៀន
- បណ្តុះបណ្តាលគ្រូ ឱ្យចេះធ្វើការជាមួយកុមារ ដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍

មេរោគអេដស៍/ជំងឺអេដស៍ពិតជាជះឥទ្ធិពលអាក្រក់ដល់ការរៀនសូត្ររបស់កុមារ ទាំងការចូលរៀន និង គុណភាពអប់រំ ។ ក្នុងគ្រួសារដែលរងគ្រោះដោយការឆ្លងមេរោគអេដស៍ គ្រួសារនោះកាន់តែក្រ ជាហេតុនាំឱ្យក្មេងឈប់រៀន ។ ក្មេងស្រីត្រូវបោះបង់ចោលសាលា ដើម្បីថែទាំឪពុកម្តាយ ឬបងប្អូនដែលឈឺ ហើយក្មេងប្រុសត្រូវបោះបង់ចោលសាលា ដើម្បីទៅរកការងារធ្វើដើម្បីជួយជីវភាពគ្រួសារ។ ចំពោះក្មេងដែលតស៊ូរៀន ត្រូវជួបការលំបាកគ្រប់បែបយ៉ាង ទាំងលទ្ធផលសិក្សាធ្លាក់ចុះ ដោយសារតែការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងគ្រួសារ និងសហគមន៍។ កុមារកំព្រាតែងប្រឈមមុខនឹងការបោះបង់ចោលសាលាព្រោះខ្វះលុយ និង បញ្ហាផ្លូវចិត្ត។

ខុសពីនៅអាហ្វ្រិក នៅអាស៊ីមិនអាចនិយាយបានអំពីឥទ្ធិពលនៃការគំរាមកំហែងនៃអេដស៍មកលើគ្រូបង្រៀន ជាពិសេស ចំនួនគ្រូបង្រៀនបានទេ ។ ប៉ុន្តែ កត្តាដែលច្បាស់គឺ អេដស៍មានឥទ្ធិពលលើចិត្តសាស្ត្ររបស់គ្រូបង្រៀន។ បើនិយាយអំពីអ្នកគ្រូវិញ ត្រូវទទួលបន្ទុកថែទាំមាតាបិតា ឬ ទទួលបន្ទុកភារកិច្ចដែលជាមាតាទោលនៅក្នុងគ្រួសារ។ កត្តានេះពិតជាជះឥទ្ធិពលដល់គុណភាពនៃការបង្រៀន និង វត្តមានរបស់អ្នកគ្រូនៅសាលា។

មធ្យោបាយដើម្បីរក្សា ទាំងក្មេងប្រុស និងក្មេងស្រីឱ្យរៀនបានយូរ គឺត្រូវជួយគេឱ្យដឹង និង យល់អំពីការឆ្លងរាលដាលពីពេលនេះទៅ និង ជួយគេឱ្យចេះការពារខ្លួនកុំឱ្យឆ្លងមេរោគ ដែលនេះជាភារកិច្ចដ៏ចំបងរបស់ប្រព័ន្ធអប់រំ។

ភស្តុតាងជាក់ស្តែងបង្ហាញថា ការរៀបចំយុទ្ធសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងជាមួយអេដស៍ ទាមទារការវិភាគគ្រប់ជ្រុងជ្រោយ និងអន្តរាគមន៍ច្បាស់លាស់នៅគ្រប់កំរិត និង គ្រប់វិស័យទាំងអស់។ ការរួមសហការក្នុងភាពជាដៃគូជាមួយគ្រប់ភាគីក្រៅពីក្រសួងអប់រំ ក៏ជាលក្ខខណ្ឌសំរាប់ជោគជ័យផងដែរ។

Guide.qxp 1/03/2005 4:10 PM Page 24

# ការកំណត់គោលបំណង និង ការស្វែងរកយុទ្ធសាស្ត្រ

ប្រសិនបើការវិភាគយេនឌ័រមិនបានធ្វើល្អិតល្អន់នៅលើវិស័យអប់រំក្នុងពេលធ្វើផែនការទេ ការវិភាគនេះក៏អាចធ្វើបាននៅក្នុងជំហាន អនុវត្តបានដែរ ។ រាល់ផែនការទាំងអស់នឹងត្រូវកំណត់ធ្វើការកែសំរួលឡើងវិញក្នុងពេលណាមួយសមស្រប ហើយ ព័ត៌មាន ទិន្នន័យ និង ការងារវិភាគថ្មីៗ អាច និង គួរតែដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រដែលបានកែលំអហើយ ។ ជំហានដំបូងដ៏សំខាន់នេះត្រូវតែធានាថាភាគីសំខាន់ៗក្នុងការអនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ តាមរយៈកិច្ចប្រជុំ ឬ សិក្ខាសាលា ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមពីគ្រប់ភាគី ។ ជំហានជាបន្ទាប់គឺថា បញ្ហាយេនឌ័រគួរតែត្រូវបានដាក់បញ្ចូលឱ្យមានរបៀបរៀបរយនៅគ្រប់ដំណាក់ការនៃការអនុវត្ត តាមដានត្រួតពិនិត្យ និង វាយតំលៃ ។ គេក៏ត្រូវតែរិះរកអាំងឌីកាទ័រយេនឌ័រជាក់លាក់សំរាប់ត្រួតពិនិត្យតាមដានពីការរីកចំរើនផងដែរ ។

យុទ្ធសាស្ត្រជាគន្លឹះមួយគឺគួរតែ**បញ្ជ្រាបបញ្ហាយេនឌ័រ**នៅក្នុងប្រព័ន្ធអប់រំថ្នាក់ជាតិទាំងអស់ ។ ការធ្វើដូចនេះនឹងធានាឱ្យមាននិរន្តរភាពសកម្មភាពសំរាប់បញ្ចៀសការរើសអើងភេទឱ្យបានទូលំទូលាយទូទាំងប្រទេស និង នៅគ្រប់វិស័យ ។ បញ្ហាយេនឌ័រគួរតែជាផ្នែកមួយ និងជាកញ្ចប់នៃកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា ។ ទោះជាយ៉ាងនេះក៏ដោយ រដ្ឋាភិបាលទាំងឡាយគួរតែចៀសវាងដាច់ខាតក្នុងការបង្ខំអនុម័តគោលនយោបាយបញ្ជ្រាបយេនឌ័រ ដោយមិនបានធានាថា បុគ្គលិករដ្ឋាភិបាលមានការយល់ដឹង និង ជំនាញចាំបាច់ចេះវិភាគបញ្ហាយេនឌ័រ ។

ដើម្បីអនុម័តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ រដ្ឋាភិបាលចាំបាច់បើកវគ្គបណ្តុះបណ្តាលលើកកំពស់ការយល់ដឹង និង ជំនាញយេនឌ័រ ដល់មន្ត្រីរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ចាប់តាំងពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់សិស្សសាលា ។ ដើម្បីធ្វើឱ្យសំរេចគោលបំណងបណ្តុះបណ្តាល និង ការគាំទ្រ ឬ សំរបសំរួលការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ការជ្រើសតាំង ឬ ជួលជំនាញការយេនឌ័រក្នុងរយៈពេលមួយសមស្រប គឺជាការចាំបាច់ ។

ការបញ្ជ្រាបយេនឌ័រតំរូវឱ្យប្រើប្រាស់ការវិភាគយេនឌ័រដើម្បីស្វែងយល់ពី

Guide.qxp 1/03/2005 4:10 PM Page 25

តម្រូវការផ្សេងៗ និង តថភាពរបស់ស្ត្រី បុរស កុមារី និង កុមារា ។ ពេលរកឃើញ តម្រូវការ និង ការពិតទាំងនេះហើយ អ្នកអប់រំអាចមានលទ្ធភាពបំពេញការងារយ៉ាងមានប្រសិទ្ធភាព ។ ការបញ្ជ្រាបយេនឌ័រតម្រូវឱ្យមានការវិភាគទៀងទាត់ និង ទូលំទូលាយ ដើម្បីឱ្យគេអាចយកការពិតនៃយេនឌ័រទាំងពួងដាក់ទៅក្នុងចិត្តគំនិតរបស់អ្នកធ្វើសេចក្តីសំរេច ។ ដោយផ្អែកលើលទ្ធផលនៃការវិភាគយេនឌ័រ គេគួរតែរៀបចំឱ្យមានអន្តរាគមន៍ជាក់លាក់ដើម្បីដោះស្រាយតម្រូវការចាំបាច់របស់ស្ត្រី និង កុមារី ឬ ក្នុងករណីខ្លះទៀត តម្រូវការពិសេសរបស់ក្មេងប្រុស ឬ បុរសមួយចំនួនតូច ។ តាមពិត ដរាបណាភាពខុសគ្នានៃយេនឌ័រមានកើតដំដែង នោះ

| គោលបំណង | យុទ្ធសាស្ត្រ |
|---|---|
| បំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំបឋមសិក្សា និង មធ្យមសិក្សា នៅឆ្នាំ ....... | • ផ្តល់ប្រាក់ឧបត្ថម្ភ/ប្រាក់លើកទឹកចិត្ត<br>• ផ្តល់មធ្យោបាយ ឬ កន្លែងស្នាក់នៅ<br>• ផ្តល់បរិយាកាសសិក្សាតែសិស្សភេទប្រុស ឬ ស្រី |
| កាត់បន្ថយអត្រាបោះបង់ចោលសាលា (សំរាប់សិស្សប្រុស ឬ ស្រី) មកត្រឹម ... % | • លើកកំពស់គុណភាពនៃបរិយាកាសសិក្សារៀនសូត្រ និង សំរាប់សិស្សស្រី ព្រមទាំងផ្តល់ការអប់រំពាក់ព័ន្ធផ្សេងៗទៀត<br>• លើកកំពស់ទំនាក់ទំនងរវាងសាលារៀន និង គេហដ្ឋានសិស្ស ព្រមទាំង បញ្ចុះបញ្ចូលម្តាយឪពុក ឬ អាណាព្យាបាលឱ្យបញ្ជូនកូនស្រីទៅសាលារៀន យ៉ាងហោចបញ្ចប់ការអប់រំបឋមសិក្សា<br>• ពិនិត្យកែលំអសៀវភៅសិក្សាឡើងវិញ ដើម្បីធានាឱ្យមានការរៀបរាប់ អំពីការពិតស្មើគ្នារវាងក្មេងប្រុស និង ក្មេងស្រី និង សិទ្ធិធ្វើជាអ្នកដឹកនាំ និង អ្នកចូលរួមយ៉ាងសកម្មនៅក្នុងគ្រួសារសហគមន៍ និង សង្គមរបស់គេ<br>• លើកកំពស់ជំនាញសំរាប់ជីវិតរស់នៅ ដោយធ្វើការបង្ហាត់ក្មេងស្រី និងក្មេងប្រុស ឱ្យចេះជួយក្មេងតូចៗ ចេះការពារផ្ទាល់ខ្លួន និង មាន ជំនាញដោះស្រាយបញ្ហា(ចរាចរណ៍ អេដស៍ ពលកម្មដោយបង្ខំ..) |
| លើកកំពស់អត្រាឡើងកើតរបស់សិស្សស្រី ពីការអប់រំបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ នៅមកត្រឹមឆ្នាំ....... | • លើកកំពស់លទ្ធភាពទទួលការអប់រំ និងគុណភាពសាលាមធ្យម<br>• ជ្រើសរើសគ្រូស្រីធ្វើជាគំរូលើមុខជំនាញ ដោយធានាថាខ្លឹមសារនៃការរៀនសូត្រ ព្រមទាំងវិធីសាស្ត្របង្រៀនមានភាពយុត្តិធម៌ និង សំរួលដល់ការរៀនសូត្ររបស់សិស្សទាំងពីរភេទ ជំរុញឱ្យមានការកែប្រែទំលាប់សង្គម និង វប្បធម៌ ដូចជាការរៀបការ នៅវ័យក្មេងជាដើម<br>• ជំរុញឱ្យធ្វើការកែប្រែច្បាប់ដែលធានាឱ្យក្មេងស្រីបន្តការសិក្សានៅ សាលាបានដូចគេឯង បន្ទាប់ពីមានផ្ទៃពោះ |
| បំបាត់គម្លាតសមិទ្ធផលនៃការរៀនសូត្រ មកត្រឹមឆ្នាំ ... | • បណ្តុះបណ្តាលគ្រូឱ្យចេះដោះស្រាយបញ្ហាយេនឌ័រ<br>• ផ្លាស់ប្តូរទំលាប់រៀនសូត្រយកគ្រូធ្វើជាមជ្ឈមណ្ឌល<br>• បង្កើតបរិយាកាសសិក្សាដោយយកសិស្សជាមជ្ឈមណ្ឌល និងរៀនជាក្រុម |
| បង្កើនចំនួនសិស្សស្រីលើមុខជំនាញគណិតឱ្យបាន ....... | • ផ្តល់ឱ្យក្មេងស្រីនូវគំរូមុខងារជាវិជ្ជមាន និង ភ្ជាប់មុខវិជ្ជាវិទ្យាសាស្ត្រ និង គណិតវិទ្យា និង វិធីសាស្ត្របង្រៀន ផ្សារភ្ជាប់ជំនាញ និង ជីវភាពជាក់ ស្តែងរបស់ក្មេងប្រុស និង ក្មេងស្រី<br>• កុំធ្វើឱ្យក្មេងយល់ច្រលំអំពីរឿងដែលថា អ្នកវិទ្យាសាស្រ្តស្រីអនាគត អត់មានប្តី ឬ រកប្តីមិនបាន |
| លើកកំពស់ចំនួនកុមារាលើវគ្គវិទ្យាសាស្ត្រសង្គមមកត្រឹមឆ្នាំ ... | • ផ្តល់ឱ្យក្មេងប្រុសនូវគំរូមុខងារជាវិជ្ជមាន និងភ្ជាប់ខ្លឹមសារវិទ្យាសាស្ត្រ សង្គម ព្រមទាំងវិធីសាស្ត្របង្ហាត់បង្រៀនជាមួយនឹង ជីវិតប្រចាំថ្ងៃរបស់ក្មេងស្រី និងប្រុស |

Guide.qxp 1/03/2005 4:10 PM Page 26

អន្តរាគមន៍ដោះស្រាយបញ្ហាយេនឌ័រជាក់លាក់ មិនត្រឹមជាការងារមួយផ្តល់នូវភាពយុត្តិធម៌ ប៉ុណ្ណោះទេ តែថែមទាំងជាការងារចាំបាច់មិនអាចខ្វះបាន។ គោលបំណង និង យុទ្ធសាស្ត្រជាក់លាក់ដើម្បីធ្វើឱ្យសំរេចទិសដៅអប់រំសំរាប់ទាំងអស់គ្នាអាស្រ័យលើលទ្ធផលនៃការវិភាគស្ថានភាពជាចាំបាច់។ តារាងខាងក្រោមបង្ហាញឧទាហរណ៍នៃគោលបំណង និង យុទ្ធសាស្ត្រមួយចំនួន បើទោះបីជាមិនទាន់គ្រប់ជ្រុងជ្រោយក៏ដោយ។

អន្តរាគមន៍ទាំងអស់នេះត្រូវបានគេយកមកអនុវត្តនៅក្នុងស្ថានភាពផ្សេងៗ ហើយ បានទទួលជោគជ័យមួយចំនួន ។ មុននឹងចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រណាមួយ ការស្វែងរកព័ត៌មានឱ្យបានកាន់តែច្រើនកាន់តែប្រសើរទាក់ទងនឹងបទពិសោធន៍របស់ប្រទេសនានាអំពីយុទ្ធសាស្ត្រទាំងនេះ និង ធ្វើការសាកល្បងអន្តរាគមន៍ថ្មីៗ ដោយធ្វើការតាមដានត្រួតពិនិត្យ និង វាយតំលៃដោយប្រុងប្រយ័ត្ន មុននឹងចាប់ផ្តើមអនុវត្តជាក់ស្តែង។

Guide.qxp 1/03/2005 4:10 PM Page 27

# អនុវត្ត
# តាមដាន និង វាយតំលៃ

បទពិសោធន៍ដែលទទួលបានក្នុងអំឡុងទសវត្ស Jomtien បង្ហាញថានៅពេលគេបានធ្វើផែនការរួចហើយ កំលាំងចិតខំប្រឹងប្រែងធ្លាក់ចុះ ហើយសកម្មភាពនានាមិនដែលត្រូវបានគេអនុវត្ត ឬគេអនុវត្តដែរ តែត្រូវបញ្ឈប់ត្រឹមពាក់កណ្តាលការ។ ពេលខ្លះ កង្វះថវិកា ឬ ធនធានមនុស្សគឺជាឧបសគ្គដល់ការអនុវត្តផែនការទាំងអស់ ប៉ុន្តែ កង្វះ **យន្តការតាមដាន** ដើម្បីត្រួតពិនិត្យ និង រំលឹកអ្នកធ្វើគោលនយោបាយជាប្រចាំអំពីការរីកចំរើន ឬ ក៏កង្វះខាតនានា ក៏ជាផ្នែកមួយនៃមូលហេតុអសកម្មក្នុងការងារអនុវត្តផងដែរ។

ក្នុងន័យនេះ ប្រទេសទាំងឡាយគួរបានទទួលដំបូន្មានបង្កើតយន្តការត្រួតពិនិត្យសំរាប់ធ្វើការវាយតំលៃជាបន្ត ដើម្បីធានាឱ្យមានយោបល់កែលំអក្នុងអំឡុងពេលអនុវត្តផែនការ។ ការធ្វើដូចនេះនឹងអាចនាំឱ្យអ្នកធ្វើគោលនយោបាយតាមដានពីការរីកចំរើនអំពីការលុបបំបាត់គម្លាតយេនឌ័រ និង វិសមភាពយេនឌ័រលើការអប់រំ និង ធ្វើការត្រួតពិនិត្យយុទ្ធសាស្ត្រឡើងវិញនៅពេលចាំបាច់។ យន្តការត្រួតពិនិត្យអាចអនុវត្តនៅតាមស្ថាប័នផ្សេងៗ អាស្រ័យទៅលើសភាពជាក់ស្តែង (គណៈកម្មាធិការផ្តល់យោបល់អន្តរក្រសួង ដែលរួមមាន អ្នកជំនាញការយេនឌ័រ ផ្នែកសមភាពយេនឌ័រ ក្រុមអនុវត្ត និងតាមដានដោយសហការជាមួយមន្ត្រីបង្គោលយេនឌ័រនៅកំរិតផ្សេងៗក្នុងប្រព័ន្ធអប់រំជាដើម) ។ ប្រទេសនីមួយៗត្រូវកំណត់ថាតើប្រព័ន្ធត្រួតពិនិត្យប្រភេទណាដែលមានលក្ខណៈសមស្របទៅនឹងតំរូវការក្នុងការធានាឱ្យមានសមភាពយេនឌ័រ ភាពប្រហាក់ប្រហែលគ្នា និង ការធ្វើសមាហរណកម្មជាមួយយន្តការអប់រំសំរាប់ទាំងអស់គ្នានៅថ្នាក់ជាតិ។

ការបង្កើត**អាំងឌីកាទ័រ** និងការប្រមូលនិងវិភាគទិន្នន័យ ជាការងារដ៏សំខាន់សំរាប់ផ្តល់ពត៌មានដល់រដ្ឋាភិបាលដើម្បីកំណត់ផ្នែកជាអាទិភាពរៀបចំយុទ្ធសាស្ត្រ និង ពិនិត្យតាមដាន ការរីកចំរើនលើការធ្វើឱ្យសំរេចសមភាពយេនឌ័រ ដើម្បីអាចទទួលបានការអប់រំប្រកបដោយគុណភាព។

ក្នុងពេល ឬបន្ទាប់ពីបង្កើតផែនការអប់រំសំរាប់ទាំងអស់គ្នា អ្នកអប់រំនឹងចាំបាច់បង្កើតប្រព័ន្ធត្រួតពិនិត្យ និង វាយតំលៃមួយដើម្បីប្រមូលទិន្នន័យដែលអាចទុកចិត្តបានសំរាប់ផ្តល់ពត៌មានអំពីការរីកចំរើនដែលគេធ្វើឡើងដើម្បីសំរេចគោលដៅសមភាពយេនឌ័រ ។ ការសំរេចចិត្តត្រូវតែធ្វើឡើងពាក់ព័ន្ធនឹងកត្តាដែលថា តើនរណាជាអ្នកប្រមូលទិន្នន័យសំរាប់ត្រួតពិនិត្យអាំងឌីកាទ័រនីមួយៗ និង ធ្វើប៉ុន្មានដង ហើយ តើនរណាជាអ្នកទទួលខុសត្រូវលើទិន្នន័យ និង វិភាគទិន្នន័យទាំងនោះ? តើការរាយការណ៍ទិន្នន័យត្រូវធ្វើឡើងនៅពេលណា? ប្រសិនបើទិន្នន័យបញ្ជាក់ពីភាពរាំងស្ទះដល់ការរីកចំរើន តើនរណាជាអ្នកទទួលទិន្នន័យនោះ ហើយ នរណាជាអ្នកទទួលខុសត្រូវ បង្កើតយន្តការដើម្បីធានាឱ្យមានការរីកចំរើន?

ដើម្បីធានាដល់ការប្រមូល និងរាយការណ៍អំពីទិន្នន័យឱ្យមានលំដាប់លំដោយអ្នកបំរើការងារចាំបាច់ត្រូវផ្តល់ការបណ្តុះបណ្តាលដោយយកចិត្តទុកដាក់ និង ត្រឹមត្រូវនៅសាលារៀន ថ្នាក់ស្រុក តំបន់ និងថ្នាក់ជាតិ ។ ជាការប្រសើរ ថវិកាកម្មវិធីប្រហែល ៥ ភាគរយ គួរតែប្រើប្រាស់សំរាប់សកម្មភាពតាមដានត្រួតពិនិត្យ និង វាយតំលៃ។

ត្រូវរៀបចំកម្មវិធីវាយតំលៃមួងម្កាលដើម្បីកំណត់ថាតើត្រូវការធ្វើការកែប្រែនៅពាក់កណ្តាលវគ្គសិក្សា ដើម្បីសំរេចគោលដៅដែលបានបង្កើតឡើង ឬ យ៉ាងណា(វាយតំលៃដំណើរការ)។ ការវាយ តំលៃក៏អាចធ្វើឡើងនៅទីបញ្ចប់នៃការធ្វើអន្តរាគមន៍ផងដែរ ដើម្បីកំណត់ពីឥទ្ធិពល និង ធ្វើការវាយតំលៃកម្មវិធី(វាយតំលៃសរុប) ។ ហៅអ្នកវាយតំលៃពីខាងក្រៅប្រព័ន្ធឱ្យធ្វើការ ឬ ចូលរួមក្នុងការវាយតំលៃកម្មវិធីអប់រំសំរាប់ទាំងអស់គ្នាទាំងនៅក្នុង ពេលដំណើរការ និង ពេលបញ្ចប់ ប៉ុន្តែ អ្នកដឹកនាំជាន់ខ្ពស់ចាំបាច់ត្រូវធានាថា អ្នកវាយតំលៃមានជំនាញ ចំណេះដឹង អាកប្បកិរិយា និង វិធានដើម្បី ធ្វើការវាយតំលៃប្រព័ន្ធឆ្លើយតបយេនឌ័រប្រកបដោយប្រសិទ្ធភាពខ្ពស់នៅ គ្រប់កំរិតទាំងអស់។

អាំងឌីកាទ័រធំៗអប់រំសំរាប់ទាំងអស់គ្នាទាំង ១៨ ត្រូវបានបំបែកទៅតាមភេទ និង ធ្វើការត្រួតពិនិត្យទៅលើការរីកចំរើនក្នុងការលុបបំបាត់គម្លាតយេនឌ័រមួយចំនួន ។ ការមិនបូកទិន្នន័យសរុបតាមភេទ មិនឆ្លុះបញ្ចាំងពីទំនាក់ទំនងដំណើរការ និង កត្តាយេនឌ័រផ្សេងៗ ដែលមានតួនាទីដ៏សំខាន់ក្នុងការរារាំងក្មេងស្រីមិនអាចទទួលបាននូវការអប់រំដែលមានគុណភាព ។ ដូចនេះប្រទេសនីមួយៗគួរធ្វើការកំណត់ អាំងឌីកាទ័រ ឬ អាំងឌីកាទ័រជំនួសមួយចំនួនសំរាប់ធ្វើការត្រួតពិនិត្យការរីកចំរើនលើការធ្វើឱ្យសំរេចគោលដៅសមភាពយេនឌ័រ ។ ជាឧទាហរណ៍ កត្តាទាំងនេះអាចជា:

Guide.qxp 1/03/2005 4:10 PM Page 29

- លុបបំបាត់គម្លាតយេនឌ័រលើលទ្ធផលនៃការសិក្សា
- ផ្លាស់ប្តូរការចូលរួមសិក្សារបស់សិស្សប្រុស និង សិស្សស្រីនៅកំរិតអប់រំថ្នាក់មធ្យមសិក្សា បណ្តុះបណ្តាលវិជ្ជាជីវៈ ឬក៏កំរិតខ្ពស់ជាងនេះ
- ចំនួនស្ត្រីក្នុងការចូលរួមក្នុងស្ថាប័នធ្វើសេចក្តីសំរេចចិត្ត
- ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងក្នុងវិស័យសាធារណៈ និង
- ចំនួនស្ត្រីវ័យចំណាស់ក្នុងការណែនាំក្មេងស្រីឱ្យធ្វើការនៅក្នុងមុខតំណែងដឹកនាំ ។

តារាងខាងក្រោមនេះផ្តល់ឧទាហរណ៍មួយអំពីទិន្នន័យបរិវិស័យ និង ទិន្នន័យគុណវិស័យ ដែលអ្នកធ្វើសេចក្តីសំរេច និង អ្នកអប់រំត្រូវការចាំបាច់ ដើម្បីចាត់វិធានការឱ្យបានសមស្រប។[១]

**ទិន្នន័យបរិវិស័យ**

- ក្មេងប្រុសច្រើនជាងក្មេងស្រីរៀនមុខវិជ្ជាវិទ្យាសាស្ត្រ និង គណិតនៅកំរិតមធ្យមសិក្សា។ *ភាពខុសគ្នាខាងយេនឌ័រគឺមានសារសំខាន់ ដូចនេះ គួរប្រើប្រាស់វិធីស្រាវជ្រាវ ទិន្នន័យ បរិវិស័យ ។*

**ទិន្នន័យគុណវិស័យ**

- ផ្តល់ជំរើសមុខវិជ្ជាវិទ្យាសាស្ត្រក្នុងពេលជាមួយគ្នាជាមួយ នឹងមុខវិជ្ជា គេហវិជ្ជា និងការងារការិយាល័យផ្សេងៗ ទៀត។
- ដាក់សិស្សស្រីនៅក្នុងជំរើសការងារការិយាល័យ។ អត្ថបទវិទ្យាសាស្ត្រសំដៅទៅលើអ្នកវិទ្យាសាស្ត្រតាមពាក្យ ពេចន៍ភេទប្រុស និងមិនធ្វើការឆ្លុះបញ្ចាំងស្ត្រីជាអ្នកវិទ្យាសាស្ត្រឡើយ។
- ការដោះស្រាយគណិតសាស្ត្រជាទូទៅត្រូវបានគេកំណត់ថាជាសកម្មភាពរបស់មនុស្សប្រុស។
- គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រភាគច្រើនគឺជាបុរស
- នៅក្នុងបន្ទប់រៀនវិទ្យាសាស្ត្រ គ្រូប្រុសកំរមានទំនាក់ទំនង ជាមួយនឹងសិស្សស្រីណាស់ ហើយកង្វះខាតទំនាក់ទំនងនេះ ជាទូទៅបង្វែរទឹកចិត្តរៀនសូត្ររបស់សិស្សស្រី។
- ក្មេងប្រុសទទួលបានការរៀនសូត្រប្រហាក់ប្រហែលគ្នា ជាមួយក្មេងស្រី ក្នុងថ្នាក់រៀនមុខវិជ្ជាគេហវិជ្ជា និង ការងារការិយាល័យ ដែលគ្រូបង្រៀនភាគច្រើនជាស្ត្រី។

១ Leo-rhynie, E., "A Quick Guide to Gender Mainstreaming in Education", Institute of Development and Labour Law, University of Cape Town, page 48, 1999. www.thecommonwealth.org/gender/publication/gsms.pdf/educaa5.pdf

Guide.qxp 1/03/2005 4:10 PM Page 30

# ការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យអប់រំ

ការបង្ហាញក្នុងប្រអប់ខាងក្រោម គឺជាដំណាក់ការសំខាន់ៗក្នុងការបញ្ជ្រាប យេនឌ័រទៅក្នុងការអនុវត្តកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា ។ សំរាប់ការណែនាំ លំអិតជាជំហានៗ ចូរមើលឧបសម្ព័ន្ធ ១ ស្តីអំពីគោលការណ៍សំរាប់បញ្ជ្រាប យេនឌ័រទៅក្នុងការអនុវត្តកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា។

ក្បាលម៉ាស៊ីនក្នុងការបញ្ជ្រាបយេនឌ័រនេះ គឺត្រូវមានវប្បធម៌រៀបចំឆ្លើយតបទៅនឹងយេនឌ័រក្នុងក្រសួងអប់រំ។លក្ខណៈនៃការឆ្លើយតបទៅនឹងយេនឌ័ររបស់ក្រសួងអប់រំរួមមាន: ការបង្កើតឱ្យមានគោលនយោបាយយេនឌ័រ យុទ្ធសាស្ត្រ សកម្មភាព ថវិកា និង បុគ្គលិក។ រាល់ការផ្តល់ការគាំទ្រលើការអប់រំ ដែលអាចជួយក្មេងស្រី និង ក្មេងប្រុសគ្រប់រូបអាចសំរេចបាននូវសក្តានុភាពនៃការអប់រំរបស់ពួកគេ ។ កត្តាដ៏សំខាន់បំផុតនោះ គឺថា បុគ្គលិកក្រសួងទាំងស្រីទាំងប្រុស ត្រូវខិតខំឱ្យអស់ពីកំលាំងកាយចិត្ត និង ជំនាញដើម្បីជំរុញសមភាពយេនឌ័រក្នុងការងាររបស់គេផ្ទាល់ និង ក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ។ ការនេះគួរតែត្រូវបានទទួលស្គាល់ និង ឱ្យតំម្លៃស្មើគ្នានឹង ការអនុវត្តមុខងារសំខាន់ៗដទៃទៀតដែរ ។ ការគាំទ្រ និង ការផ្តល់ឧទាហរណ៍ល្អៗជាគំរូនៃរដ្ឋមន្ត្រី និង មន្ត្រីក្រសួងអប់រំសំខាន់ៗ គឺជាការចាំបាច់ក្នុងការបង្កើតវប្បធម៌រៀបចំឆ្លើយតបយេនឌ័រ។

Guide.qxp 1/03/2005 4:10 PM Page 31

| ដំណើរការ | ការអនុវត្តការងារ |
| --- | --- |
| • បង្កើតឱ្យមានការប្តេជ្ញាចិត្តខាងនយោបាយខ្លាំងក្លា មួយចំពោះគោលនយោបាយ និង ក្របខ័ណ្ឌស្ថាប័ន ស្តីពីសមភាពយេនឌ័រ។ | • បង្កើតឱ្យមានបណ្តាញការងារនៃជនបង្គោលនៅថ្នាក់ជាតិក្នុងក្រសួង និង ស្ថាប័នផ្សេងៗ។ |
| • កសាងសមត្ថភាពស្ថាប័នដោយការផ្តល់ការតំរង់ទិស និង ការបណ្តុះបណ្តាលយេនឌ័រ ដើម្បីអនុវត្ត តាមដាន និង វាយតំលៃ ផែនការអប់រំសំរាប់ទាំងអស់គ្នានៅថ្នាក់ជាតិ | • ជួលអ្នកជំនាញការយេនឌ័រក្នុងវិស័យអប់រំឱ្យបណ្តុះបណ្តាលបញ្ជ្រាបយេនឌ័រទៅដល់អ្នកអនុវត្តទាំងឡាយពីថ្នាក់ក្រសួងរហូតដល់អ្នកនយោបាយ ក៏ដូច ជាភាគីពាក់ព័ន្ធផ្សេងៗ ដូចជា មន្ត្រីរដ្ឋាភិបាល ថ្នាក់មូលដ្ឋាន។ |
| • ធ្វើការជជែកគ្នាពីគោលនយោបាយ និង លើកកំពស់ ការឯកភាពគ្នាអំពីកំណែទំរង់ស្ថាប័ន និង រដ្ឋបាល ក្នុងគោលដៅធានាឱ្យមានការដាក់បញ្ចូលយេនឌ័រទៅក្នុងដំណើរការបង្កើតគោលនយោបាយ និង ធ្វើការសំរេចចិត្ត ក៏ដូចជាការអនុវត្តការងារ។ | • បង្កើតឱ្យមានផ្នែកសមភាពយេនឌ័រ ដែលអាចមានលទ្ធភាពប្រើប្រាស់ធនធានផ្សេងៗ(ធនធានមនុស្ស និង ថវិកា) ដើម្បីផ្តល់យោបល់បញ្ជ្រាប លើកកំពស់ និង ធ្វើការជាមួយនឹងផ្នែក/នាយកដ្ឋានអប់រំផ្សេងៗទៀត ដើម្បីធានាការអនុវត្តការងារ។<br>• រៀបចំឱ្យមានក្រុមអនុវត្តការងារ និង តាមដានដោយ សហការជាមួយជនបង្គោលយេនឌ័រនៅថ្នាក់ផ្សេងៗគ្នា ក្នុងប្រព័ន្ធអប់រំ។ |
| • រៀបចំយុទ្ធសាស្ត្រលើកកំពស់ផែនការការអប់រំសំរាប់ ទាំងអស់គ្នាដើម្បីឆ្លើយតបយេនឌ័រ ដោយប្រើ ប្រាស់មធ្យោបាយពិគ្រោះយោបល់ និង ការប្រាស្រ័យ ទាក់ទងផ្សេងៗ (ឧទាហរណ៍ ដើម្បីបញ្ចូលខ្លឹមសារកម្មវិធីគោល ជាពិសេស ខ្លឹមសារទាក់ទងនឹងសមភាពយេនឌ័រ និង ដើម្បីធ្វើឱ្យសង្គមស៊ីវិលយល់ដឹងពីសមភាពយេនឌ័រ) | • បង្កើតគណៈកម្មាធិការប្រឹក្សាអន្តរក្រសួងមួយដែលមាន អ្នកជំនាញការខាងយេនឌ័រ។<br>• បង្កើតគណៈកម្មាធិការប្រឹក្សាសង្គមស៊ីវិល ឬ ប្រសិន មានគណៈកម្មាធិការនេះរួច ហើយត្រូវធានាថា គណៈ កម្មាធិការនេះមានសមាជិកជាតំណាងមកពីអង្គការនារី និងអ្នកជំនាញយេនឌ័រ |
| • បង្កើត អាំងឌីកាទ័រ (ទាំងបរិវិស័យ និង គុណវិស័យ) និង មធ្យោបាយសំរាប់ការអនុវត្តការអប់រំសំរាប់ ទាំងអស់គ្នាដែលឆ្លើយតបនឹងតំរូវការយេនឌ័រ។ | • កំណត់ពីលទ្ធផលអភិវឌ្ឍន៍តាមជំហានៗ។ រកថវិកាសំរាប់អនុវត្តឱ្យសំរេចគោលដៅ ទី២ ទី៣ និង ទី ៥ នៃឯកសារដាកា(Dakar)ក្នុងរយៈពេល ... ឆ្នាំ។ |

១ សំរាប់ព័ត៌មានលំអិតអំពីកម្មវិធី flaship សូមពិនិត្យតាមវែបសាយដែលមាននៅទំព័រខាងចុងនៃសៀវភៅនេះ។

# តំរូវការថវិកា និង ធនធានមនុស្ស និង ភាពជាដៃគូ

ការគណនា និង ការដាក់បញ្ចូលទៅក្នុងផែនការអប់រំសំរាប់ទាំងអស់គ្នានូវការចំណាយនានាដើម្បីសំរេចទិសដៅសមភាពយេនឌ័រ គឺជាការចាំបាច់ ។ ព្រមពេលជាមួយគ្នានេះដែរ ការកំណត់ពេលវេលាច្បាស់លាស់លើការផ្សព្វផ្សាយយេនឌ័រឱ្យបានទូលំទូលាយ និង មានទិន្នន័យគាំទ្រឥទ្ធិពលវិជ្ជមានដែលបានមកពីការអប់រំយេនឌ័រ ក៏ជាការសំខាន់ផងដែរនៅក្នុងសង្គម ។ ម្យ៉ាងវិញទៀត ការប្រើប្រាស់ធនធានមនុស្សចាំបាច់ និង **ការបណ្តុះបណ្តាល ការធ្វើវិក្រឹតការ និង ការលើកកំពស់ចំណេះដឹង**បុគ្គលិក រួមមាន អ្នកគ្រប់គ្រង និង អ្នកត្រួតពិនិត្យ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងយេនឌ័រតំរូវឱ្យមានការគិតពិចារណាឱ្យបានល្អិតល្អន់ ។ ដើម្បីអនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នា និង យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឱ្យបានកាន់តែប្រសើរ ក្រសួងអប់រំអាចធ្វើការផ្លាស់ប្តូរស្ថាប័នមួយចំនួន។ តាមពិត ការផ្លាស់ប្តូរដូចនេះ គឺជាការចាំបាច់នៅក្នុងប្រទេសមួយចំនួន។ជាឧទាហរណ៍ ការផ្លាស់ប្តូរអាចត្រូវការចាំបាច់ក្នុងការយកផ្នែកអប់រំរបស់ក្មេងស្រីចេញពីគំរោងដែលយកចិត្តទុកដាក់ទៅលើការអប់រំកុមារីប៉ុណ្ណោះទៅជាស្ថាប័នផ្តល់ប្រឹក្សាច្រើនផ្នែក និងត្រួតពិនិត្យដែលមានការគ្រប់គ្រងការអប់រំកំរិតខ្ពស់ ។ **ចំណុចបង្គោលយេនឌ័រ ឬ មន្ត្រីសម្របសម្រួលយេនឌ័រ**អាចត្រូវបានគេជ្រើសរើសនៅថ្នាក់ខេត្ត ឬ ស្រុក ក៏ដូចជាក្នុងនាយកដ្ឋាន អង្គភាព ឬ ស្ថាប័នជំនាញផ្សេងទៀតរបស់ក្រសួងអប់រំ(ដូចជា មជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានកម្មវិធីសិក្សា ជាដើម) ។ ការកំណត់ឱ្យមានធនធាន និង សិទ្ធិអំណាច នៅគ្រប់កំរិតនីមួយៗសំរាប់សកម្មភាពអនុវត្ត គឺជាការចាំបាច់បំផុត។

បញ្ហាយេនឌ័រក្នុងវិស័យអប់រំមានលក្ខណៈស្មុគស្មាញ។ មានកត្តាជាច្រើនដែលទាក់ទងទៅនឹងស្ថានភាពសាលារៀន សេដ្ឋកិច្ចសង្គម និង វប្បធម៌ដែលទាមទារឱ្យមានការចូលរួមពីភាគីផ្សេងៗ ដើម្បីកំណត់រកបញ្ហា និង យុទ្ធសាស្ត្រ។ ភាពជាដៃគូពីអន្តរស្ថាប័ន ក្រុមគាំទ្រ ។ល។ សំរាប់ការអប់រំក្មេងស្រី ដែលមានការពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ជំនួញ បណ្តាញព័ត៌មាន អង្គការសាសនា ស្ថាប័នរដ្ឋាភិបាល និង

Guide.qxp 1/03/2005 4:10 PM Page 33

អង្គការអន្តរជាតិនានា បានបង្ហាញឱ្យឃើញពីជោគជ័យយ៉ាងធំធេងនៅក្នុងប្រទេសជាច្រើន [១]។

មានប្រទេសកាន់តែច្រើនឡើងៗបានអនុម័ត*វិធីសាស្ត្រចំរុះស្ថាប័ន* ដើម្បីអប់រំអ្នកផ្តល់ជំនួយ និង ទីភ្នាក់ងារបច្ចេកទេសមួយចំនួនអំពីផែនការអភិវឌ្ឍន៍លំអិតសំរាប់វិស័យអប់រំ ដោយមានរដ្ឋាភិបាលជាអ្នកដឹកនាំ។ ការស្រាវជ្រាវបង្ហាញថា នៅពេលដៃគូទាំងអស់មានការប្តេជ្ញាខ្ពស់ និង មានចំណាប់អារម្មណ៍លើបញ្ហាយេនឌ័រ ពេលនោះការកែប្រែអាចកើតមានឡើងក្នុងវិស័យអប់រំ ។ ទោះជាយ៉ាងនេះក៏ដោយ ករណីនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ការតស៊ូមតិទូលំទូលាយ និង សកម្មភាពលើកកំពស់ការយល់ដឹងក៏ជាការចាំបាច់ក្នុងចំណោមដៃគូទាំងអស់ផងដែរ ។ ការបណ្តុះបណ្តាលយេនឌ័រទាក់ទងនឹងការពិនិត្យឡើងវិញនៃការអនុវត្តប្រចាំឆ្នាំ ឬ កន្លះឆ្នាំរបស់អ្នកចូលរួមទាំងអស់ (មន្ត្រីរដ្ឋាភិបាល និង តំណាងម្ចាស់អំណោយ) អាចជា វិធីមួយធ្វើឱ្យមានការឯកភាព និង សកម្មភាពរួមក្នុងចំណោមភាគីពាក់ព័ន្ធ។

ការអប់រំដើម្បីឆ្លើយតបទៅនឹងយេនឌ័រ គឺជាផ្នែកគន្លឹះដល់ការកាត់បន្ថយភាពក្រីក្រ និង ធ្វើឱ្យមានការកែប្រែ និង រីកចំរើនវិជ្ជមានក្នុងស្រទាប់ប្រជាជន។ ទោះជាយ៉ាងនេះក៏ដោយ គំរោងអភិវឌ្ឍជាច្រើនផ្តល់សេវា ឬ យកចិត្តទុកដាក់តែសំបកក្រៅដល់បញ្ហាយេនឌ័រ ហើយជាពិសេស ចំពោះតួនាទីនៃការអប់រំដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។ ក្រសួងអប់រំ និង ភាគីពាក់ព័ន្ធខាងវិស័យអប់រំក្រៅរដ្ឋាភិបាលត្រូវតែមានការប្រុងប្រយ័ត្ន។ វិស័យអប់រំទាំងមូលចាំបាច់ត្រួតពិនិត្យឱ្យដឹងថា មានការលើកកំពស់ការអប់រំយេនឌ័រស្មើៗគ្នា ដោយមិនត្រូវប្រកាន់យកតែគំនិតអភិវឌ្ឍ ដែលមិនបានគិតគូរដល់យេនឌ័រឡើយ។ ការនេះទាមទារឱ្យភាគីពាក់ព័ន្ធក្នុង និង ក្រៅប្រព័ន្ធអប់រំចូលរួមសហការជាមួយផ្នែកសាធារណៈ ផ្នែកស៊ីវិល និង ឯកជន និង សហគមន៍អន្តរជាតិ ។ មានផ្នែកសំខាន់ជាច្រើនតំរូវឱ្យជំនាញការអប់រំ និង យេនឌ័រជួយសំរេចគោលដៅ អភិវឌ្ឍន៍ប្រចាំសហស្សវត្ស យុទ្ធសាស្ត្រ និង កម្មវិធីកាត់បន្ថយភាពក្រីក្រ និង ទិសដៅអភិវឌ្ឍសំខាន់ៗ ជាច្រើនទៀត។

១. សំរាប់ព័ត៌មានបន្ថែមអំពីគោលការណ៍ និង ការអនុវត្ត សូមមើល Williams, H., *Multisectoral Strategies for Advancing Girls'Education,* SAGE, Washington DC, 2001.

Guide.qxp 1/03/2005 4:10 PM Page 34

# ពត៌មានបន្ថែម និង ធនធានផ្សេងៗទៀត

## គោលគំនិតជាគន្លឹះមួយចំនួន

***ភេទ:*** សំដៅទៅលើភាពខុសគ្នាខាងជីវសាស្ត្ររវាងមនុស្សប្រុស និង មនុស្សស្រី ដែលមានលក្ខណៈដូចគ្នា និង ត្រូវបានកំណត់ពីកំណើត។

***យេនឌ័រ:*** សំដៅទៅលើមុខងារ និង ការទទួលខុសត្រូវរបស់មនុស្សប្រុស-ស្រីនៅក្នុងគ្រួសារ សង្គម និង វប្បធម៌របស់យើង។ គោលគំនិតយេនឌ័រក៏រួមបញ្ចូលទាំងក្តីរំពឹងទាំងពួងទាក់ទងនឹង ចរិតលក្ខណៈ កាយសម្បទា និង អាកប្បកិរិយា របស់បុរស និង ស្ត្រី (ភាពជាបុរស និង ភាពជាស្ត្រី)។

មុខងារ និង ក្តីរំពឹងទាំងនេះកើតចេញពីការរៀនសូត្រ។ មុខងារ និង ក្តីរំពឹងទាំងនេះអាចប្រែប្រួលទៅតាមពេលវេលា និង មានលក្ខណៈខុសគ្នាក្នុងវប្បធម៌មួយ និង ពីវប្បធម៌មួយទៅវប្បធម៌មួយទៀត ។ គោលគំនិតយេនឌ័រនេះមានសារៈសំខាន់ណាស់សំរាប់ជួយដល់ការវិភាគយេនឌ័រ ដោយធ្វើការឆ្លុះបញ្ចាំងពី ពីរបៀបដែលបង្កើតឱ្យមានស្ថានភាពមិនស្មើគ្នារបស់ស្ត្រីនៅក្នុងសង្គម។ ទោះជាយ៉ាងនេះក៏ដោយ ស្ថានភាពមិនស្មើគ្នានេះអាចមានការកែប្រែ ឬ លុបបំបាត់ចោលបាន មិនដូចជាការកំណត់ខាងជីវសាស្ត្រនោះទេ។

***ការវិភាគយេនឌ័រ:*** គឺជាការប្រមូល និង វិភាគពត៌មានអំពីភាពលំអៀងខាងភេទ។ បុរស និង ស្ត្រី បំពេញមុខងារផ្សេងៗគ្នា។ ការនេះធ្វើឱ្យបុរស និង ស្ត្រីមានបទពិសោធន៍ ចំណេះដឹង ទេពកោសល្យ និង តំរូវការផ្សេងៗគ្នា។ ការវិភាគយេនឌ័រគឺស្វែងយល់ពីភាពខុសគ្នាទាំងនោះ ដើម្បីជួយគោលនយោបាយ កម្មវិធី និង គម្រោងនានាក្នុងការកំណត់ និង បំពេញតម្រូវការខុសៗគ្នារបស់បុរស និង ស្ត្រី។ ការវិភាគយេនឌ័រក៏ចូលរួមសំរួលការប្រើប្រាស់ចំណេះដឹង និង ជំនាញដ៏ប៉ិនប្រសប់របស់បុរស និង ស្ត្រីផងដែរ។

***ទិន្នន័យពីភាពលំអៀងខាងភេទ:*** គឺជាទិន្នន័យដែលគេបានប្រមូល និង រៀបចំកត់ត្រាដោយឡែកពីគ្នា អំពីបុរស និង ស្ត្រី។

**ការបញ្ជ្រាបយេនឌ័រៈ** ធ្វើឡើងដោយផ្អែកលើការវិភាគយេនឌ័រ ។ ការបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធសាស្ត្រមួយសំរាប់ប្រែក្លាយការព្រួយបារម្ភ និង បទពិសោធន៍របស់បុរស និង ស្ត្រីឱ្យទៅជាផ្នែកដ៏សំខាន់សំរាប់អនុវត្តតាមដានត្រួតពិនិត្យ និង វាយតំលៃគោលនយោបាយ និង កម្មវិធីនានាក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និង សង្គម ដើម្បីឱ្យស្ត្រី និង បុរសទទួលបានផលប្រយោជន៍ស្មើៗគ្នា។ គោលដៅចុងក្រោយ គឺធ្វើឱ្យសំរេចសមភាពយេនឌ័រ។

**សន្ទស្សន៍សមភាពយេនឌ័រគិតជាតួលេខ (GPI) សំរាប់វិស័យអប់រំ :** គឺជាសមាមាត្រនៃអត្រាចេះអក្សររបស់ក្មេងស្រីធៀបជាមួយនឹងអត្រាចេះអក្សររបស់ក្មេងប្រុសវ័យជំទង់ ដែលវាស់ពីការរីកចំរើននៃសមភាពយេនឌ័រលើការអប់រំ និង ឱកាសរៀនសូត្ររបស់ស្ត្រី ប្រៀបធៀបនឹងឱកាសរៀនសូត្ររបស់បុរស ។ សន្ទស្សន៍នេះក៏អាចប្រើជាអាំងឌីកាទ័រដ៏សំខាន់សំរាប់ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងសង្គមផងដែរ។

**សមភាពយេនឌ័រៈ** មានន័យថា ស្ត្រី និង បុរសមានឱកាសស្មើៗគ្នា ដោយទទួលបាននូវសិទ្ធិជាមនុស្សពេញលេញ និង ឱកាសស្មើគ្នាក្នុងការរួមចំណែកចំពោះ និង ទទួលផលពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និង នយោបាយ។

ដូចនេះ សមភាពយេនឌ័រ គឺជាការឱ្យតម្លៃស្មើគ្នារបស់សង្គមទៅលើភាពដូចគ្នា និង ភាពខុសគ្នារបស់បុរស និង ស្ត្រី ក៏ដូចជាទៅលើតួនាទីផងដែរ ។ សមភាពយេនឌ័រនេះ គឺសំដៅទៅលើភាពជាដៃគូពេញលេញរបស់បុរស និង ស្ត្រីនៅក្នុងគេហដ្ឋាន ក្នុងសហគមន៍ និង ក្នុងសង្គម ។

**សមធម៌យេនឌ័រៈ** គឺជាដំណើរការធ្វើឱ្យមានភាពយុត្តិធម៌សំរាប់បុរស និង ស្ត្រី ។ ដើម្បីធានាភាពយុត្តិធម៌ ត្រូវចាត់វិធានការសមស្របនានាដើម្បីប៉ះប៉ូវលើការខាតបង់ខាងប្រវត្តិសាស្ត្រ និង សង្គម ដែលរារាំងស្ត្រី និង បុរសពីការបំពេញការងារក្នុងកន្លែងធ្វើការ។ សមធម៌ គឺជាមធ្យោបាយ ចំណែកសមភាព និង អ្វីដែលកើតចេញពីសមភាព គឺជាលទ្ធផល។

**ការផ្តល់សិទ្ធិអំណាចៈ** គឺនិយាយពីការគ្រប់គ្រងជីវិតរស់នៅរបស់បុរស និង ស្ត្រី ពោលគឺកំណត់ផែនការជីវិតរបស់គេផ្ទាល់ ការស្វែងរកជំនាញ កសាងទំនុកចិត្តផ្ទាល់ខ្លួន ដំណោះស្រាយបញ្ហា និង ការអភិវឌ្ឍគំនិតពឹងផ្អែកផ្ទាល់ខ្លួន ។ គ្មានមនុស្សណាម្នាក់អាចផ្តល់សិទ្ធិអំណាចដល់មនុស្សម្នាក់ទៀតឡើយ គឺមានតែបុគ្គលម្នាក់ៗប៉ុណ្ណោះ ដែលអាចធ្វើឱ្យខ្លួនឯងមានសិទ្ធិ

---

១. **សូមមើល** UN’s Economic and Social Council (ECOSOC) conclusions 1997/2.

Guide.qxp 1/03/2005 4:10 PM Page 36

អំណាច ដើម្បីធ្វើការជ្រើសរើស ឬ សំដែងមតិ។ ទោះបីជាយ៉ាងនេះក៏ដោយ ស្ថាប័ននានា ដែលរួមមានទាំងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អាចជួយដំណើរការទាំងឡាយ ដែលអាចធ្វើឱ្យមានភាពរឹងមាំនៃការផ្តល់សិទ្ធិអំណាចផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ឬ មនុស្សជាក្រុម។

***ការបែងចែកពលកម្មតាមយេនឌ័រៈ*** គឺជាលទ្ធផលនៃការបែងចែកការងារក្នុងសង្គមនីមួយៗក្នុងចំណោមបុរស និង ស្ត្រី ទៅតាមអ្វីដែលគេគិតថាសមស្រប ។

***ស្ត្រីក្នុងការអភិវឌ្ឍ*** *(WID)*: យុទ្ធសាស្ត្រស្ត្រីក្នុងការងារអភិវឌ្ឍមានគោលដៅបញ្ចូលស្ត្រីទៅក្នុងដំណើរការអភិវឌ្ឍដែលមានស្រាប់ ដោយឱ្យស្ត្រីធ្វើការងារសមស្រប។ ជាធម្មតា ស្ត្រីគឺជាអ្នកទទួលផលប្រយោជន៍ប្រយោល ក្នុងគំរោងស្ត្រីក្នុងការងារអភិវឌ្ឍ ដែលជាញឹកញាប់ ជួយស្ត្រីឱ្យក្លាយទៅជាអ្នកផលិតដែលមានសមត្ថភាព និង ជួយលើកកំពស់ប្រាក់ចំណូលរបស់ស្ត្រី ។ ទោះបីជាគំរោងស្ត្រីក្នុងការងារអភិវឌ្ឍជាច្រើនបានលើកកំពស់សុខភាព ប្រាក់ចំណូល ឬ ធនធានក្នុងរយៈពេលខ្លី ដោយសារគំរោងទាំងនោះមិនបានផ្លាស់ប្តូរទំនាក់ទំនងមិនស្មើភាព គំរោងមួយចំនួនពុំមាននិរន្តរភាពឡើយ។ បញ្ហាសាមញ្ញមួយនៃគំរោងស្ត្រីក្នុងការអភិវឌ្ឍ គឺថាគំរោងនោះមិនបានយកចិត្តទុកដាក់ទៅលើមុខងារចំរុះរបស់ស្ត្រី ឬ ថាគំរោងនោះមិនបានគិតគូរឱ្យបានដឹតដល់នូវភាពបត់បែនពេលវេលា និង កំលាំងពលកម្មរបស់ស្ត្រី។

ភាពខុសគ្នាធំបំផុតរវាងស្ត្រីក្នុងការអភិវឌ្ឍ (WID) និង យេនឌ័រ និង ការអភិវឌ្ឍ (GAD) គឺថា គំរោងស្ត្រីក្នុងការងារអភិវឌ្ឍជាធម្មតាមិនឈរលើមូលដ្ឋាននៃការវិភាគយេនឌ័រឱ្យបានល្អិតល្អន់ឡើយ។ វិធីសាស្ត្រយេនឌ័រ និង ការអភិវឌ្ឍគឺពឹងផ្អែកទៅលើការវិភាគយេនឌ័រ។

តាមពិត ចាំបាច់ត្រូវមានអន្តរាគមន៍សំរាប់បញ្ហាស្ត្រី និងបុរសដាច់ដោយឡែកពីគ្នាម្តងម្កាល ដែលអាចបំពេញគំនិតផ្តួចផ្តើមយេនឌ័រ។ ការស្រាវជ្រាវបង្ហាញថា ភាពជោគជ័យនៃសកម្មភាពកំណត់តាមភេទ និង យេនឌ័រមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកំរិតនៃការវិភាគយេនឌ័រ។

***យេនឌ័រ និង អភិវឌ្ឍ*** *(GAD)*: វិធីសាស្ត្រយេនឌ័រ និង ការអភិវឌ្ឍ យកចិត្តទុកដាក់លើការធ្វើអន្តរាគមន៍ដោះស្រាយទំនាក់ទំនងយេនឌ័រមិនស្មើភាព ដែលទប់ស្កាត់ការអភិវឌ្ឍអសមធម៌ និងជាញឹកញាប់រារាំងស្ត្រីមិនឱ្យចូលរួមក្នុងសកម្មភាពការងារបានពេញលេញ។ យេនឌ័រ និង អភិវឌ្ឍន៍ព្យាយាមជំរុញស្ត្រី និង បុរសឱ្យចូលរួមធ្វើការសំរេចចិត្ត និង ចែករំលែកផលប្រយោជន៍ ។ វិធីសាស្ត្រនេះ ជាញឹកញាប់មានគោលដៅបំពេញតំរូវការជាក់ស្តែង និងលើកកំពស់ផលប្រយោជន៍ជាយុទ្ធសាស្ត្រ ។ វិធីសាស្ត្រយេនឌ័រ

Guide.qxp 1/03/2005 4:10 PM Page 37

និង ការអភិវឌ្ឍមួយទទួលបានជោគជ័យ តំរូវឲ្យមានការប្តេជ្ញាជាប់ជាប្រចាំពីគ្រប់មជ្ឈដ្ឋាន។

***តំរូវការជាក់ស្តែងៈ*** គឺជាតំរូវការចាំបាច់ប្រចាំថ្ងៃ ដូចជា ទឹក ទីជំរក និង អាហារ ។

***ផលប្រយោជន៍យុទ្ធសាស្ត្រ*** : ការធ្វើអន្តរាគមន៍ដើម្បីកំណត់ពីផលប្រយោជន៍ យុទ្ធសាស្ត្រយកចិត្តទុកដាក់លើបញ្ហាជាគន្លឹះទាក់ទងនឹងស្ថានភាពមិនស្មើគ្នារបស់ស្ត្រី(ជួនកាល ស្ថានភាពមិនស្មើគ្នារបស់បុរស) និង វិសមធម៌យេនឌ័រ។ ផលប្រយោជន៍ជាយុទ្ធសាស្ត្រ គឺជាផលប្រយោជន៍រយៈពេលវែងជាធម្មតា មិនមែនជាសំភារៈ និង ជាញឹកញាប់ពាក់ព័ន្ធនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងសង្គមទាក់ទងនឹងស្ថានភាព និង សមធម៌ស្ត្រី ។ ការផ្លាស់ប្តូរទាំងនេះរួមមាន ការផ្លាស់ប្តូរច្បាប់ឲ្យមានសិទ្ធិសេរីភាពស្មើគ្នា ឲ្យមានជំរើសបង្កើតកូន និង លើកកំពស់ការចូលរួមលើការសំរេចចិត្ត។

## នរណាអាចជួយបាន?

សូមទំនាក់ទំនងជាមួយការិយាល័យយូណេស្កូ ឬ យូនីសេហ្វ ដែលនៅតាមប្រទេសរបស់អ្នក ដើម្បីពិភាក្សាអំពីជំនួយតំរូវការបច្ចេកទេស ។ ខាងក្រោមនេះជាវែបសាយដែលមានអត្ថប្រយោជន៍ក្នុងបញ្ហានេះ :

## វែបសាយៈ

| | |
|---|---|
| ***http://www.undp.org*** | gives access to information related to gender and UNGEI, such as key documents, resources, training material, good practices, and link to other relevant websites. |
| ***http://www.undg.org/gender/*** | Contains comprehensive geder main-streaming, learning, and information packages. |
| ***http://www.sage.aed.org/*** | A substantive website providing manuals and work docments on strategies to promote girls' educaiton. |
| ***http://www.fawe.org*** | Provides experiences in girls' educaiton in Africa. |
| ***http://www.unescobkk.org/gender*** | Provides information on experiences in girls' education in Asia and thePacific as well as resources, guides and studies aimed at promoting Gender Equality in Education. |

| | |
|---|---|
| ***http://www.ioe.ac.uk*** | Gives update on the Gender, Development and Education: Beyond Access Project, funded by DFID and coordinated by academics from the Institute of Education, London and Oxfam UK. |
| ***http://www.id21.org*** | Id21 is a fast-track research reporting service, witha special focus on education, aimed at bringing UK-based development research findings and policy recommendations to policy makers and development practitioners worldwide. Includes many items on girls, gender and HIV/AIDS in the context of education. |

### *Flagship Programme websites:*

| | |
|---|---|
| Literacy | www.unesco.org/education/litdecade |
| FRESH | For more information on Effective School Health, contact Anna Maria Offman, email: *am.hoffmann@unesco.org* You can also consult the following website: *http://www.schoolsandhealth.org* which provides information on FRESH, HIV/AIDS and Education, school nutrition, country programmes and resources on health isseus in the context of the school. |
| ECCE | *www.ecdgroup.com* *www.ecdgroup.org/coordinators_notebook.* asp is a site in the previous website called 'Coordinators'Noteook' and provides a synthesis of the most recent information on topics of interest to people concerned about the well-being of young children and their families. |

| | |
|---|---|
| | You can register and receive updated information for free. |
| HIV/AIDS | For information on AIDS and education: *http://www.unesco.org, pages related to HIV/AIDS; http://www.unicef.org; http://www.unicef.org/lifeskills/ index_8657.html.* |

## Publication and Documents


ABEL/USAID, *Beyond Enrolment: A Handbook for Improving Girls' Experiences in Primary Classrooms*, Creative Associates International, Washington DC, 1996.

Creative Associates International, *Toolkit for assessing and Promoting Equity in the Classroom*, 2003, available on-line at www.caii.net.

Kane, E., *Guide for Task Managers: Identifying Problems and Interventions in Girls' Education*, Asia Technical Department, World Bank, Washington DC, 1996.

Leo-Rhynie, E., "*A Quick Guide to Gender Mainstreaming in Education*,"Institute of Development and Labour Law, University of Cape Town, South Africa, page 48, 1999.

Rush, A., *Starting Now: Strategies for Helping Girls Complete Primary Education*,SAGE, Washington DC, 2000,available on-line at *http://sage.aed.org*

Stromquist, N. P., "Increasing girls'and women's participation in basic education," in *Fundamentals of Educational Planning (no.56)*, UNESCO International Institute for Educational Planning, Paris, 1997.

Williams, H., *Multisectoral Strategies for Advancing Girls' Education: Principle & Practice*, SAGE, Washington DC, 2001, available on-line at *http://sage.aed.org*

Guide.qxp 1/03/2005 4:10 PM Page 40

UNESCO, *“Education for all: Gender equality in non-formal basic education: A strategic framework”*, working document, 2001.

UNESCO, *A Toolkit for Promoting Gender Equality in Education*, Gender in Education Network, UNESCO Bangkok, 2003.

UNESCO, *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments,*UNESCO Bangkok, 2003.

UNICEF, HIV/AIDS Education: A Gender Perspective. Tips and Tools, 2002 (contact: www.unicef.org).

Guide.qxp 1/03/2005 4:10 PM Page 41

## ឧបសម្ព័ន្ធ ១

# បញ្ជីត្រួតពិនិត្យការបញ្ជ្រាបយេនឌ័រនៅក្នុង ការអប់រំសំរាប់ទាំងអស់គ្នា

## ជំហានទី ១: សិក្សាស្រាវជ្រាវ និង ការប្រមូលទិន្នន័យ

- បុរស និង ស្ត្រីដែលមានចំណាប់អារម្មណ៍លើយេនឌ័របង្កើតក្រុមរៀបចំធ្វើការស្រាវជ្រាវ អ្នកប្រមូល និង វិភាគទិន្នន័យ ។ ការបណ្តុះបណ្តាលពីយេនឌ័រត្រូវរៀបចំធ្វើឡើង បើត្រូវការចាំបាច់ ។
- ផ្តល់ទិន្នន័យបរិវិស័យ និង គុណវិស័យអំពីការរើសអើងភេទ ។
- បំបែកទិន្នន័យថ្នាក់ជាតិទៅតាមផ្នែកតូចៗ (តំបន់ទីក្រុង_ជនបទ ក្រុមសេដ្ឋកិច្ច វប្បធម៌ និង សង្គម) ។
- ទិន្នន័យគុណវិស័យស្វែងយល់ពីភាពខុសគ្នានៃយេនឌ័រ ។
- វិភាគសំភារៈបង្រៀន_រៀន ដើម្បីកំណត់ថាតើមានការលំអៀងយេនឌ័រឬទេ ។
- វាយតំលៃដំណើរការរៀន_បង្រៀន និងដំណើរការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីពិនិត្យមើលថាតើវិធីសាស្ត្របង្រៀនមានលក្ខណៈសមស្របសំរាប់អ្នករៀនទាំងពីរភេទឬទេ ។
- ក្រសួងអប់រំត្រូវពង្រឹងការងារយេនឌ័ររបស់ខ្លួន ព្រមទាំងសិក្សាស្រាវជ្រាវពីការអប់រំ ដោយការផ្លាស់ប្តូរព័ត៌មានជាមួយនឹងភាគីអប់រំផ្សេងៗទៀត (អង្គការក្រៅរដ្ឋាភិបាល ធ្វើការលើវិស័យអប់រំ មជ្ឈមណ្ឌលស្រាវជ្រាវ និង ប្រភពស៊ីវិលផ្សេងៗទៀត)។
- នៅពេលរកឃើញគម្លាតយេនឌ័រ ត្រូវធ្វើការសិក្សាស្រាវជ្រាវថ្មីៗទៀត ដោយប្រើប្រាស់ បញ្ជីសំណួរយេនឌ័រ (Gender Lens)។

## ជំហានទី ២ : គោលនយោបាយ និង ការរៀបចំផែនការ

- រដ្ឋមន្ត្រីក្រសួងអប់រំ និង ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំត្រូវផ្សព្វផ្សាយខ្លឹមសារច្បាស់លាស់ឱ្យដល់គ្រប់ផ្នែករបស់ក្រសួង និង ធ្វើការអប់រំដល់ភាគីពាក់ព័ន្ធ ដែលក្រសួងអប់រំប្តេជ្ញាផ្តល់ការអប់រំអំពី សមភាពយេនឌ័រ។ ខ្លឹមសារទាំងនោះត្រូវធ្វើឡើងនៅរាល់កិច្ចប្រជុំការអប់រំសំរាប់ទាំងអស់គ្នា។
- សមាជិកក្រុមរៀបចំផែនការត្រូវមានបុរស និង ស្ត្រីដែលយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ។ ក្រុមក៏ត្រូវមានសមាជិកជាជនបង្គោលយេនឌ័រផងដែរ។ បើចាំបាច់ គួរបន្ថែមអ្នកជំនាញការយេនឌ័រនៅក្នុងក្រុមនោះ។

- សមាជិកទាំងអស់នៃក្រុមរៀបចំផែនការត្រូវតំរង់ទិសទៅរកគោលគំនិតយេនឌ័រ និង បញ្ហាយេនឌ័រចំបងៗ និង បញ្ហានៃការអប់រំយេនឌ័រនៅក្នុងប្រទេសរបស់គេ។
- ផែនការការអប់រំសំរាប់ទាំងអស់គ្នាត្រូវមានគោលដៅ គោលបំណង ឆ្លើយតបទៅនឹង បញ្ហាយេនឌ័រ និង មានយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ដើម្បីធ្វើឱ្យសំរេចគោលបំណង ទាំងនេះ។
- ចំណុចសំខាន់នៃផែនការអប់រំសំរាប់អស់គ្នា គឺការប្តេជ្ញាបំពេញតំរូវការចាំបាច់របស់ ក្មេងប្រុស និង ក្មេងស្រី ក៏ដូចជាបុរស និងស្ត្រីដែលមានតួនាទីបង្រៀនក្មេងប្រុស-ស្រី ទាំងនោះ ។
- គោលនយោបាយ និង ការធ្វើផែនការការអប់រំសំរាប់ទាំងអស់គ្នា ត្រូវយកចិត្តទុកដាក់ លើការស្រាវជ្រាវពីយេនឌ័រ និង ការអប់រំដូចបានលើកឡើងក្នុងដំណាក់ការទី ១ ។
- ភាគីអប់រំសំខាន់ៗទាំងក្នុង និង ក្រៅរដ្ឋាភិបាលត្រូវចូលរួមក្នុងដំណើរការរៀបចំផែនការ អប់រំសំរាប់ទាំងអស់គ្នា។
- អ្នកធ្វើផែនការត្រូវវាយតំលៃសក្តានុពលភាពនៃវិធានការសកម្មភាពដោយប្រុងប្រយ័ត្ន ដើម្បីជួយបំពេញ តំរូវការពិសេសរបស់ក្មេងប្រុស ក្មេងស្រី បុរស និង ស្ត្រីដែលទទួលរង នូវការរើសអើង។
- ផែនការអប់រំសំរាប់ទាំងអស់គ្នាត្រូវមានអាំងឌីកាទ័រសំរាប់វាស់ពីការរីកចំរើនខាងយេនឌ័រ។

ត្រូវកំណត់ថវិកាសំរាប់អនុវត្តផែនការអប់រំសំរាប់ទាំងអស់គ្នាឱ្យបានច្បាស់លាស់សំរាប់
- ក្រុមគោលដៅ និង សកម្មភាពនានា ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ។ គេក៏ត្រូវកំណត់ថវិកា ជាក់ស្តែងសំរាប់ធ្វើការតស៊ូមតិ និង ការបណ្តុះបណ្តាលយេនឌ័រផងដែរ។
- ការធ្វើផែនការ និង ការរៀបចំថវិកាសំរាប់រៀបចំ និង កសាងកន្លែងអប់រំ ឬ បណ្តុះ បណ្តាលត្រូវធ្វើឡើងដោយគិតពីបញ្ហាយេនឌ័រ។

## ដំណាក់កាលទី ៣ : ការអនុវត្ត

- ត្រូវបង្កើតឱ្យមានគណៈកម្មាធិការអនុវត្ត ឬ ក៏ក្រុមអនុវត្ត ដោយមានជនបង្គោលយេនឌ័រ ជាសមាជិក។បន្ថែមអ្នកជំនាញការយេនឌ័រ បើចាំបាច់ ។
- ផ្តល់ការបណ្តុះបណ្តាលយេនឌ័រដល់ក្រុមគ្រប់គ្រងជាន់ខ្ពស់ ។
- មានថវិកា និង ដំណើរការសំរាប់ផ្តល់ព័ត៌មាន វិធាន និង ធនធានយេនឌ័រជាក់ស្តែងទៅឱ្យ បុគ្គលិកក្រសួងអប់រំ។
- បង្កើតឱ្យមានបណ្តាញបណ្តុះបណ្តាលគ្រូបង្គោលសំរាប់ផ្តល់ការបណ្តុះបណ្តាលយេនឌ័រទៅ ដល់អ្នកផ្តល់ការអប់រំផ្លូវការ និង ក្រៅផ្លូវការទាំងអស់។
- បញ្ចូលផ្នែកយេនឌ័រទៅក្នុងសកម្មភាពបណ្តុះបណ្តាល និង សកម្មភាព កសាងសមត្ថភាព ទាំងអស់។

- (សាលា) ជំរុញឱ្យមានការចូលរួមពីមាតាបិតាសិស្ស និង អ្នកដទៃទៀតក្នុងសហគមន៍របស់គេ ដើម្បីឱ្យភាគីអប់រំទាំងអស់មើលឃើញពីតំលៃនៃការអប់រំស្មើៗគ្នារបស់ក្មេងប្រុស និង ក្មេងស្រី (ដូចជា សមាគមគ្រូបង្រៀន និង មាតាបិតាសិស្ស គណៈកម្មាធិការគ្រប់គ្រងសាលា អ្នកជំនួញមូលដ្ឋាន អ្នកដឹកនាំសហគមន៍ជាដើម)។
- ផ្តល់អាទិភាពដល់ការបង្កើតឱ្យមានៈ
  - វគ្គបណ្តុះបណ្តាលគ្រូថ្មី និង វគ្គបំប៉នគ្រូត្រូវឱ្យមានបញ្ហាបយេនឌ័រ ។
  - សំភារៈរៀន និង បង្រៀន ត្រូវគ្មានលំអៀងយេនឌ័រ ។
  - កំណត់ និងផ្តល់បរិយាកាសរៀនសូត្រប្រកបដោយលក្ខណៈមិត្តភាពជាមួយកុមារ ដែលវិធី នេះនឹងផ្តល់សិទ្ធិអំណាចដល់ទាំងក្មេងប្រុស និង ក្មេងស្រី ។
  - ត្រូវមានយន្តការទទួលស្គាល់គ្រូ និង អ្នករដ្ឋបាល ដែលចូលរួមជួយលើកកំពស់សមភាពយេនឌ័រ។

## ដំណាក់កាលទី ៤ : ការត្រួតពិនិត្យ និង វាយតំលៃ

- ត្រូវមានសមាជិកភេទប្រុស និងភេទស្រីនៅក្នុងក្រុមត្រួតពិនិត្យ និង វាយតំលៃ ។ ធ្វើការបណ្តុះបណ្តាលដល់សមាជិកក្រុមត្រួតពិនិត្យ និង វាយតំលៃទាំងអស់អំពី ការវិភាគយេនឌ័រ និង បញ្ជ្រាបយេនឌ័រ។
- មានប្រព័ន្ធត្រួតពិនិត្យ និង វាយតំលៃសមស្របធ្វើអត្តសញ្ញាណលទ្ធផលសមភាពយេនឌ័រជាក់លាក់ អាំងឌីកាទ័រយេនឌ័រ និង វិធីអនុវត្តដែលប្រើប្រាស់ថវិកាតិចតួចដើម្បីប្រមូលទិន្នន័យប្រកបដោយខ្លឹមសារ។
- បើអាចធ្វើបាន ពិគ្រោះជាមួយអ្នកទទួលផលប្រយោជន៍ (សិស្ស គ្រូ សហគមន៍)ដើម្បីកំណត់អាំងឌីកាទ័រ និង វិធីសាស្ត្រប្រមូលទិន្នន័យ។
- ត្រួតពិនិត្យការរីកចំរើនយេនឌ័រឱ្យបានទៀងទាត់ ដោយចាត់ទុកដូចជាផ្នែកមួយសំខាន់នៃសកម្មភាពត្រួតពិនិត្យរបស់ក្រសួងអប់រំ។
- បញ្ចូលគំរូការបញ្ជ្រាបយេនឌ័រច្បាស់លាស់ទៅក្នុងបញ្ជីត្រួតពិនិត្យ និង វាយតំលៃរបស់ក្រសួង។
- ប្រមូលទិន្នន័យគុណភាព និង បរិមាណអំពីការរើសអើងភេទ ។
- ចែកចាយរបាយការណ៍បានពីការត្រួវពិនិត្យវាយតំលៃទៅឱ្យអ្នកធ្វើគោលនយោបាយ អ្នកទទួលផលប្រយោជន៍ និង ភាគីពាក់ព័ន្ធ ដើម្បីសុំជាយោបល់កែលំអ។

Guide.qxp 1/03/2005 4:10 PM Page 44

## ជំហានទី ៥ : ចែករំលែក និង ប្រើប្រាស់មេរៀនដែលបានរៀនចេះ

- ធ្វើបទបង្ហាញរបាយការណ៍ត្រួតពិនិត្យ និង វាយតំលៃចុងក្រោយ ដែលមានការវិភាគពី ការរីកចំរើនយេនឌ័រ ក្នុងការពិភាក្សាតុមូល ដោយមានការចូលរួមពីមន្ត្រីអប់រំជាន់ខ្ពស់ និង ភាគីអប់រំសំខាន់ៗថ្នាក់ជាតិ (អ្នកផ្តល់ជំនួយ អង្គការអប់រំអន្តរជាតិ ស្ថាប័នអប់រំ និង អង្គការក្រៅរដ្ឋាភិបាលធ្វើការលើផ្នែកអប់រំ) ដើម្បីស្វែងរកមតិកែលំអ និង អនុសាសន៍ ។
- ត្រូវប្រមូលមតិកែលំអ និង អនុសាសន៍នានាអំពីការរីកចំរើនយេនឌ័រពីសាលារៀន សហគមន៍ និង អ្នករដ្ឋបាល។
- បញ្ចូលលទ្ធផល និង អនុសាសន៍ដែលបានមកពីការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ទាំងក្នុង និង ក្រៅ ក្រសួងអប់រំទៅក្នុងដំណើរការធ្វើគោលនយោបាយ និងរៀបចំផែនការ ក្រសួងអប់រំ។ លទ្ធផល និង អនុសាសន៍ទាំងនោះ គឺជាមូលដ្ឋានសំរាប់ឱ្យក្រសួងអប់រំធ្វើការ ពិនិត្យឡើងវិញនូវ គោលបំណង យុទ្ធសាស្ត្រ សកម្មភាពបណ្តុះបណ្តាល និង សកម្មភាព អនុវត្តផ្សេងៗទៀតរបស់ខ្លួន។
- របាយការណ៍សង្ខេបជូនបណ្តាញផ្សព្វផ្សាយម្តងម្កាលដោយថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួងអប់រំ អំពីបញ្ហាយេនឌ័រ និង ការអប់រំ និង ការរីកចំរើនខាងយេនឌ័រ។ ជនបង្គោលក៏ជា សមាជិកក្រុមរបាយការណ៍ផងដែរ។

## ឧបសម្ព័ន្ធ ២

# សំណួរសំខាន់ៗអំពីយេនឌ័រសំរាប់ពិចារណាបង្កើត កម្មវិធីសិក្សា និង សៀវភៅសិក្សា ដោយគ្មានលំអៀងយេនឌ័រ

- តើសមាជិកគណៈកម្មាធិការដឹកនាំមានចំនួនស្មើគ្នារវាងបុរស និង ស្ត្រីដែលយកចិត្តទុកដាក់លើយេនឌ័រដែរឬទេ?
- តើការវាយតំលៃតំរូវការមានការចូលរួមស្មើរវាងបុរស និង ស្ត្រី ដើម្បីកំណត់ពីតំរូវការ និង ផលប្រយោជន៍របស់គេដែរឬទេ?
- តើអ្នកជំនាញការមុខវិជ្ជានៅក្នុងអនុគណៈកម្មាធិការនីមួយៗទទួលបានការបណ្តុះបណ្តាលសមស្របលើបញ្ហាយេនឌ័រដែរឬទេ?
- តើប្រធានបទ និង កម្មវិធីសិក្សា និង សំភារៈសំរាប់សិស្សបំពេញតំរូវការរបស់ក្មេងប្រុស និង ក្មេងស្រីដែរឬទេ?
- តើប្រធានបទ និង សំភារៈសំរាប់គ្រូបង្រៀនឆ្លើយតបនឹងតំរូវការគ្រូប្រុស និង គ្រូស្រីដែរឬទេ?
- តើបញ្ហាយេនឌ័រត្រូវបានគេយកទៅពិចារណាក្នុងសិក្ខាសាលា ដែលក្នុងនោះអ្នកជំនាញខាងយេនឌ័រ ឯកភាពលើខ្លឹមសារនៃកម្មវិធីសិក្សា និង សំភារៈទាំងនោះដែរឬទេ?
- តើអ្នកនិពន្ធ និង វិចិត្រករគឺជាមនុស្សយកចិត្តទុកដាក់លើយេនឌ័រដែរឬទេ? តើមានចំនួនតុល្យភាពយេនឌ័រ រវាងអ្នកនិពន្ធ និង វិចិត្រករដែរឬទេ?
- តើអត្ថបទ ភាសា និង រូបភាពគ្មានលំអៀងខាងយេនឌ័រដែរឬទេ?
  - តើភាសាមានបញ្ចូលយេនឌ័រដែរឬទេ?
  - តើលំហាត់ និង រឿងនិទានផ្សេងៗឆ្លុះបញ្ចាំងពីក្មេងប្រុស និង ក្មេងស្រីស្មើៗ និង ឆ្លុះបញ្ចាំងពីបទពិសោធន៍ក្នុងជីវិតរបស់គេដែរឬទេ?
  - តើក្មេងប្រុស និង ក្មេងស្រីមានឱកាសស្មើៗ ក្នុងការដោះស្រាយលំហាត់ដែរឬទេ?
  - តើមុខងារការទទួលខុសត្រូវ និង សកម្មភាពរបស់ក្មេងប្រុស និង ក្មេងស្រី ឆ្លុះបញ្ចាំងស្មើៗគ្នានូវសិទ្ធិអំណាច និង ការធ្វើការសំរេចចិត្តដែរឬទេ?
  - តើមុខងារក្មេងប្រុស និង ក្មេងស្រីក្នុងសហគមន៍ ក្នុងគេហដ្ឋាន និង ដោយស្ម័គ្រចិត្ត មានទំហំ និង តំលៃស្មើគ្នាដែរឬទេ?

- តើក្មេងប្រុស និង ក្មេងស្រីដែលបានរៀបរាប់ក្នុងរូបភាព និង ក្រាហ្វិកមានលក្ខណៈ និង ស្ថានភាពដូចគ្នាដែរឬទេ?
- តើសិស្សប្រុស និង សិស្សស្រីដែលចូលរួមក្នុងការសាកល្បងកម្មវិធីសិក្សា និង សៀវភៅ សិក្សាមានចំនួនស្មើគ្នាដែរឬទេ?
- តើសមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យឡើងវិញចុងក្រោយមានការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រដែរឬទេ?
- តើបុរស និង ស្ត្រីនឹងបានទទួលការបណ្តុះបណ្តាលឱ្យធ្វើជាគ្រូបណ្តុះបណ្តាល ដោយ ប្រើប្រាស់កម្មវិធីសិក្សា ឬ សំភារៈសិក្សាថ្មីៗដែរឬទេ?
- តើគ្រូប្រុស និង ស្រីបង្រៀនមុខវិជ្ជាយេនឌ័រនេះបានទទួលការបណ្តុះបណ្តាលក្នុងការ បង្រៀនកម្មវិធីថ្មី លើវិធីឆ្លើយតបតំរូវការយេនឌ័រដែរឬទេ?
- តើសៀវភៅសិក្សាថ្មីៗមានគ្រប់គ្រាន់សំរាប់សិស្សប្រុស និងស្រីទាំងអស់ដែរឬទេ?

Guide.qxp 1/03/2005 4:10 PM Page 47